## សំឡេងអាជីវករស្ត្រីលក់ដូរតាមដងផ្លូវក្នុងស្ថានភាពកូវីដ១៩

# របាយការណ៍វាយតម្លៃស្តីពី

## ផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើអាជីវករស្ត្រីលក់ដូរតាមដងផ្លូវ និងការធានាបាននូវសិទ្ធិសេដ្ឋកិច្ចសង្គម



# ២០២១

ឧបត្ថម្ភថវិកាដោយៈ

USAID

pact building local promise.

API BUILDING CAPACITY FOR CHANGE ADVOCACY AND POLICY INSTITUTE

Coalition for Partnership in Democratic Development

IDEA

© ២០២១ វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API)
អគារភ្នំពេញវីឡា ផ្ទះលេខ ១២៤ ផ្លូវ ៣៨៨ សង្កាត់ទួលស្វាយព្រៃទី០១ ខណ្ឌចំការមន រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
លេខទូរស័ព្ទ៖ +855 23 213 486
គេហទំព័រ៖ https://apiinstitute.org

ទស្សនៈដែលបង្ហាញនៅក្នុងឯកសារនេះ គឺជាទស្សនៈរបស់អ្នកនិពន្ធ ហើយទស្សនៈទាំងនេះមិនឆ្លុះបញ្ចាំងទស្សនៈ និងជំហររបស់ក្រុមប្រឹក្សាភិបាល និងម្ចាស់ជំនួយឡើយ។

ឯកសារនេះត្រូវបានផលិតឡើងក្រោមជំនួយសប្បុរស របស់ប្រជាពលរដ្ឋអាមេរិក តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិក សម្រាប់ការអភិវឌ្ឍអន្តរជាតិ(USAID)។ ខ្លឹមសារក្នុងវីដេអូនេះ មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ USAID រឺ រដ្ឋាភិបាល សហរដ្ឋអាមេរិកឡើយ។

# តារាងមាតិកា


| | | |
|---|---|---|
| អ | អក្សរកាត់ | ៤ |
| ស | សេចក្តីថ្លែងអំណរគុណ | ៥ |
| ស | សេចក្តីសង្ខេបប្រតិបត្តិ | ៦ |
| ១ | សេចក្តីផ្តើម | ១១ |
| ២ | សនិទានភាពនៃការសិក្សាវាយតម្លៃ | ១៣ |
| ៣ | វិធីសាស្រ្ត | ១៣ |
| | ៣.១. បទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ | ១៣ |
| | ៣.២. ការប្រឹក្សាយោបល់ | ១៤ |
| | ៣.១. អ្នកឆ្លើយតបគោលដៅ និងលំនៅដ្ឋានរបស់អ្នកឆ្លើយតប | ១៤ |
| ៤ | ក្រមសីលធម៌បទសម្ភាសន៍ | ១៥ |
| ៥ | ដែនកំណត់នៃការសិក្សាវាយតម្លៃ | ១៥ |
| ៦ | ប្រជាសាស្រ្តនៃអ្នកឆ្លើយតប | ១៦ |
| ៧ | លទ្ធផលរកឃើញសំខាន់ៗ | ១៧ |
| | ៧.១. ទីតាំងលក់ដូរ និងការកេងប្រវ័ញ្ច | ១៧ |
| | ៧.២. សុវត្ថិភាពចំណីអាហារ និងឥរិយាបថរបស់អាជីវករលក់ដូរតាមដងផ្លូវ | ១៨ |
| | ៧.៣. ភាពជាតំណាង និងការចរចាជាសមូហភាព | ២០ |
| | ៧.៤. ការយល់ដឹងអំពីច្បាប់ និងគោលនយោបាយ | ២១ |
| | ៧.៥. បញ្ហាកូវីដ-១៩ និងការគាំទ្រជំនួយសង្គ្រោះបន្ទាន់ | ២១ |
| | ៧.៦. ការឆ្លើយតបរបស់រដ្ឋាភិបាលក្នុងឆ្នាំ ២០២០ | ២១ |
| ៨ | សំណូមពរ និងតម្រូវការក្នុងឆ្នាំ២០២១ | ២៣ |
| ៩ | តម្រូវការបណ្តុះបណ្តាល និងជំនាញ | ២៤ |
| ១០ | អនុសាសន៍ | ២៥ |
| ១១ | ឯកសារយោង | ២៨ |
| ១២ | ឧបសម្ព័ន្ធ | ៣០ |
| | បញ្ជីច្បាប់ និងគោលនយោបាយដែលបានពិគ្រោះយោបល់ | ៣០ |
| | បញ្ជីរបាយការណ៍ដែលបានពិគ្រោះយោបល់ | ៣០ |

# អក្សរកាត់

| | |
|---|---|
| API | វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ |
| ASEAN | សមាគមប្រជាជាតិអាស៊ីអគ្នេយ៍ |
| CSDGs | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា |
| CPDD | សម្ព័ន្ធសម្រាប់ភាពជាដៃគូក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ |
| CDA | សមាគមអភិវឌ្ឍន៍ឃុំ |
| CDP | ផែនការអភិវឌ្ឍន៍ឃុំ |
| CRC | កាកបាទក្រហមកម្ពុជា |
| IDEA | សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ |
| KII | ការសម្ភាសអ្នកដឹងព័ត៌មានសំខាន់ |
| LA | អាជ្ញាធរមូលដ្ឋាន |
| MoI | ក្រសួងមហាផ្ទៃ |
| MSMEs | សហគ្រាសមីក្រូ ធន់តូច និងមធ្យម |
| MoEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoP | ក្រសួងផែនការ |
| N.S.S.F | បេឡាជាតិសន្តិសុខសង្គម |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SMEs | សហគ្រាសធន់តូច និងមធ្យម |
| WE Act | គម្រោងសហគ្រិននារីសកម្មកម្ពុជា |

## ស សេចក្តីថ្លែងអំណរគុណ

ឯកសារនេះ ត្រូវបានរៀបចំឡើងដោយបុគ្គលិកនៃវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយដោយមានការជួយគាំទ្រយ៉ាងខ្លាំងក្លាពីបុគ្គលជាច្រើនដែលបង្កើតឱ្យចេញជារូបរាងនៃការសិក្សាវាយតម្លៃបឋមនេះ។ ពួកគេបានផ្តួចផ្តើមគំនិតនូវការងារនេះ និងបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការពិនិត្យឡើងវិញ និងផ្តល់នូវមតិយោបល់ដែលពោរពេញដោយគំនិតល្អៗទៅលើឧបករណ៍ប្រមូលទិន្នន័យ និងសេចក្តីព្រាងរបាយការណ៍វាយតម្លៃនេះ។

យើងក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគណៈគ្រប់គ្រង និងបុគ្គលិកនៃវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ សម្ព័ន្ធសម្រាប់ភាពជាដៃគូនៅក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD) និងសមាគមប្រជាធិតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) ចំពោះការខិតខំជួយពិនិត្យឡើងវិញនូវសំណួរ និងឧបករណ៍ប្រមូលទិន្នន័យ ជាពិសេស ការរៀបចំផ្នែកភស្តុភារ និងការសម្របសម្រួលការសម្ភាសអ្នកដឹងព័ត៌មានសំខាន់ៗ។

យើងក៏សូមថ្លែងអំណរគុណដោយស្មោះស្ម័គ្រចំពោះស្ត្រីជាអ្នកលក់ដូរតាមដងផ្លូវដ៏អស្ចារ្យជាច្រើននាក់ដែលបានចូលរួមយ៉ាងសកម្ម និងដោយទឹកចិត្តស្មោះស្ម័គ្រនៅក្នុងកិច្ច សម្ភាសនៃការសិក្សានេះ ទោះបីជាពេលវេលាមិនអំណោយផលល្អក៏ដោយ។ យើងមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងដោយបានដឹងពីការលំបាករបស់ពួកគេ ហើយយើងសង្ឃឹមថាលទ្ធផលនៃការសិក្សាស្រាវជ្រាវទាំងនេះ នឹងបង្កើតឱ្យមានការធ្វើអន្តរាគមន៍ផ្នែកគោលនយោបាយដ៏ល្អមួយដើម្បីដោះស្រាយនូវបញ្ហាប្រឈមរបស់ពួកគេ។

យើងក៏សូមថ្លែងអំណរគុណចំពោះការជួយគាំទ្រពីម្ចាស់ជំនួយរបស់យើងគឺ អង្គការ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ(USAID) តាមរយៈអង្គការ Pact Cambodia ចំពោះការផ្តល់មូលនិធិសម្រាប់គម្រោងនេះ និងការជួយគាំទ្រជាបន្តបន្ទាប់នៅក្នុងការពង្រឹងភាពធន់ និងសុខុមាលភាពរបស់ក្រុមងាយរងគ្រោះនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅក្នុងប្រទេសកម្ពុជា។

ទិន្នន័យ និងសេចក្តីពន្យល់នៅក្នុងរបាយការណ៍វាយតម្លៃនេះ ត្រូវបានពិនិត្យ យ៉ាងប្រុងប្រយ័ត្នតាមចំណេះដឹង និងការខំប្រឹងប្រែងរបស់យើង។ រាល់កំហុសឆ្គងណាមួយនៅក្នុងរបាយការណ៍នេះគឺជាការទទួលខុសត្រូវរបស់យើងតែម្នាក់គត់។

ភ្នំពេញថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១

## ស សេចក្តីសង្ខេបប្រតិបត្តិ

វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅក្នុងប្រទេសកម្ពុជាបានក្លាយជាវិស័យជួរមុខនៃក្បាលម៉ាស៊ីនសេដ្ឋកិច្ចរបស់ប្រទេសរាប់ទស្សវត្សរ៍មកហើយ។ វិស័យនេះបានរួមចំណែកដល់ឱកាសបង្កើតមុខរបរ និងការងារ និងការអភិវឌ្ឍនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការសិក្សារបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ក្នុងឆ្នាំ ២០១៩ បង្ហាញថាមុខរបរ និងការងារក្រៅប្រព័ន្ធនៅក្នុងប្រទេសកម្ពុជាមានចំនួនជិត ៩០% នៃមុខរបរ និងការងារសរុបដែលភាគច្រើនគឺជាស្ត្រី។ ផ្នែកមួយនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនេះគឺការលក់ដូរតាមដងផ្លូវដែលគ្រប់ដណ្តប់តួនាទីសំខាន់ៗនៅក្នុងការបង្កើតប្រាក់ចំណូល និងសន្តិសុខស្បៀងដែលផ្តល់អត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជារាប់លាននាក់។ ការសិក្សាផ្សេងទៀតកត់សម្គាល់ថាវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធមានចំនួន ជិត ៦២% នៃ GDP របស់ប្រទេសកម្ពុជាក្នុងឆ្នាំ ២០០៣។ នេះមានន័យថា មុខរបរលក់ដូរតាមដងផ្លូវដើរតួនាទីជាផ្នែកមួយដ៏សំខាន់នៃសង្គមរបស់កម្ពុជា។

មុខរបរលក់ដូរតាមដងផ្លូវ គឺជាការងារអាជីវកម្មមួយដ៏សម្បើមនៅក្នុងប្រទេសកម្ពុជាក៏ប៉ុន្តែមុខរបរនេះនៅតែស្ថិតនៅបាតតារាងនៃរបៀបវារៈ បើនិយាយអំពីការជួយគាំទ្ររបស់រដ្ឋាភិបាលដល់វិស័យនេះ។ ភស្តុតាងជាស្ថិតិបង្ហាញថា អាជីវករលក់ដូរតាមដងផ្លូវក្នុង ប្រទេសកម្ពុជាមានចំនួនរហូតដល់ ១,៦៧៣,៣៩០នាក់ ឬស្មើ ១០% នៃចំនួនប្រជាពលរដ្ឋសរុប។ យោងតាមការសិក្សារបស់អង្គការ Oxfam នៅក្នុងឆ្នាំ ២០១៩ មានការប៉ាន់ប្រមាណថា អាជីវករលក់ដូរតាមដងផ្លូវដែលក្នុងនោះមានចំនួន ៧៥ ភាគរយជាស្ត្រី ដែលនៅក្នុងទីក្រុងភ្នំពេញតែមួយគត់មានចំនួន ១% នៃតួលេខទាំងនេះ ឬ១០% នៃចំនួនប្រជាពលរដ្ឋសរុបនៅក្នុងទីក្រុងភ្នំពេញ។ ទោះបីជាវិស័យនេះដើរតួនាទីដ៏សំខាន់រួមចំណែកដល់ការបង្កើតមុខរបរ និងការងារ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមក៏ដោយ ក៏អាជីវករលក់ដូរតាមដងផ្លូវជាពិសេសស្ត្រីមិនទទួលបានការការពារដោយច្បាប់ ដែលបង្កើតឱ្យមានជាការកេងប្រវ័ញ្ចជាបន្តបន្ទាប់ និងកង្វះការទទួលបានអត្ថប្រយោជន៍សង្គមនានា។ សំខាន់ជាងនេះទៀត ពួកគេក៏កំពុងរងគ្រោះពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិមួយចំនួនដែលមិនសូវមានអំណោយផល និងដែលគម្រាមកំហែងដល់ឱកាសបង្កើតប្រាក់ចំណូល និងការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ពួកគេ។ ដោយសារបញ្ហានេះហើយ ទើបមានតម្រូវការឱ្យធ្វើការសិក្សាវាយតម្លៃ និងការធ្វើអន្តរាគមន៍ផ្នែកគោលនយោបាយនេះ ដើម្បីធានាឱ្យមានការជួយគាំទ្រពិសេសដើម្បីពង្រឹងសិទ្ធិទទួលបានការងារសមរម្យ និងភាពធន់របស់ពួកគេ។ ហើយយើងសង្ឃឹមថាការសិក្សានេះនឹងជួយផ្តល់ព័ត៌មានដល់វិស័យសាធារណៈ និងអ្នកធ្វើគោលនយោបាយអំពីបញ្ហាប្រឈមថ្មីៗដែលស្ត្រីជាអ្នកលក់ដូរតាមដងផ្លូវបានជួបប្រទះ និងមានវិធានការអន្តរាគមន៍ផ្នែកគោលនយោបាយសំខាន់ៗដើម្បីជួយគាំទ្រពួកគេ។

ផ្នែកខាងក្រោមនេះ បង្ហាញអំពីរបកគំហើញចម្បងៗរួមជាមួយអនុសាសន៍ផ្នែកគោលនយោបាយ។

**របកគំហើញចម្បងទី ១៖** កង្វះទីតាំងលក់ដូរសមរម្យបានបង្កើតឱ្យមានការរំលោភបំពាន និងការកេងប្រវ័ញ្ចជាប្រព័ន្ធមកលើ (ស្ត្រី) អាជីវករលក់ដូរតាមដងផ្លូវនៅទូទាំងប្រទេស។ យោងតាមទិន្នន័យបង្ហាញថា អ្នកឆ្លើយសំណួរចំនួន ៤៩.៥៩% គឺជាអ្នកលក់ដូរនៅលើដងផ្លូវខណៈមាន ១៨.៤៤% នៃអ្នកឆ្លើយសំណួរសរុបគឺជាអ្នកលក់ដូរចល័ត ហើយមានជិត ១៣.៩៣% នៃអ្នកទាំងនោះមានទីតាំងលក់ដូរនៅក្នុងផ្សារ។ ហើយដើម្បីរក្សាបាននូវកន្លែងលក់ដូរ និងការការពារ (ស្ត្រី) អាជីវករលក់ដូរតាមដងផ្លូវទាំងនោះ ត្រូវសូកប៉ាន់នគរបាល សន្តិសុខផ្សារ និងបុគ្គលដែលមិនមានឯកសណ្ឋានត្រឹមត្រូវ។ ការវិភាគបែបគុណភាពបង្ហាញនូវលទ្ធផលមិនល្អ។ ទិន្នន័យបង្ហាញថា មានអ្នកឆ្លើយសំណួរចំនួន ៥៤.១០% នៃអ្នកឆ្លើយសរុបបង់ប្រាក់ចន្លោះពី ៥០០-១,០០០ រៀល, និងមានចំនួន ២៩.៩២% នៃអ្នកទាំងនោះបង់ប្រាក់ចាប់ពី ១,១០០-២,០០០ រៀលជាមធ្យមក្នុងមួយថ្ងៃ។

**អនុសាសន៍ចម្បងទី ១៖** សាលាក្រុងភ្នំពេញ និងក្រុងផ្សេងទៀតគួរពិចារណាផ្តល់នូវទីតាំងលក់ដូរដ៏សមរម្យដល់អាជីវករលក់ដូរតាមដងផ្លូវនៅតំបន់ជាយក្រុង។ ការអនុវត្តល្អៗនៅ ប្រទេសជិតខាង គួរយកមកពិចារណា ដោយសារតែប្រទេសទាំងនោះមានបញ្ហាប្រឈមដែល មានលក្ខណៈដូចគ្នា។ ការអនុវត្តល្អគឺការរៀបចំទីតាំងមួយកន្លែង ឬយកផ្លូវមួយកន្លែងសម្រាប់ឱ្យមានការលក់ដូរនៅទីនោះ។ វាផ្តល់ដល់អាជ្ញាធរនូវឱកាសក្នុងការវាយតម្លៃពីផលប៉ះពាល់ និងកាត់បន្ថយហានិភ័យជាសក្តានុពល ដែលបង្កដោយគំនិតផ្តួចផ្តើមនោះមុនមានការបន្សី្ស និងអនុវត្តគោលនយោបាយក្នុងទ្រង់ទ្រាយធំ។ ធ្វើបែបនេះ វានឹងដោះស្រាយបាននូវបញ្ហានៃការកេងប្រវ័ញ្ចទៅលើអាជីវករលក់ដូរតាមដងផ្លូវ និងដោះស្រាយបញ្ហាកកស្ទះចរាចរណ៍នៅតាមដងផ្លូវ។

**របកគំហើញចម្បងទី ២៖** កង្វះការយល់ដឹង និងឥរិយាបថល្អចំពោះសុវត្ថិភាពចំណីអាហារក្នុងចំណោម (ស្ត្រី) អាជីវករលក់ដូរតាមដងផ្លូវ បានបង្កើតជាហានិភ័យដ៏ធំដល់សុខភាពសាធារណៈរយៈពេលវែងនៅក្នុងប្រទេសកម្ពុជា។ តួលេខពីការសិក្សាវាយតម្លៃបង្ហាញថាមានអ្នកឆ្លើយសំណួរតែ ៤០.៩៨% ប៉ុណ្ណោះនៃអ្នកឆ្លើយសរុបបានបញ្ជាក់ថាបានទទួលការបណ្តុះបណ្តាលអំពីសុវត្ថិភាពចំណីអាហារ។ នេះឆ្លុះបញ្ចាំងឱ្យឃើញពីបញ្ហាប្រឈមជាបន្តបន្ទាប់នៃការយល់ដឹងអំពីការរក្សាអនាម័យល្អ និងសុវត្ថិភាពចំណីអាហារជាពិសេសក្នុងចំណោម (ស្ត្រី) អាជីវករលក់ដូរតាមដងផ្លូវនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**អនុសាសន៍ចម្បងទី ២៖** គេគួរចាត់ជាអាទិភាព និងផ្តល់ការបណ្តុះបណ្តាលអំពីសុវត្ថិភាពចំណីអាហារ និងការលក់ដូរចំណីអាហារនៅតាមផ្លូវដល់អាជីវករលក់ដូរតាមដងផ្លូវដើម្បីលើកកម្ពស់ឱ្យប្រសើរនូវសុវត្ថិភាពចំណីអាហារ និងសុខភាពសាធារណៈនៅកម្ពុជា។ ក្រៅពីនេះវាចាំបាច់ត្រូវធានាឱ្យមានការប្រមូលសម្រាមប្រកបដោយប្រសិទ្ធផល និងធានាឱ្យអាជីវករលក់ដូរតាមដងផ្លូវមានទឹកស្អាតប្រើប្រាស់ និងមានកន្លែងទុកដាក់សម្រាមឱ្យបានត្រឹមត្រូវ។ គេគួរពិចារណាឱ្យមានគោលនយោបាយលើកទឹកចិត្ត និងគោលនយោបាយច្បាប់ដើម្បីលើកទឹកចិត្តដល់ការចូលរួម និងភាពមានប្រសិទ្ធិភាព។ ការងារនេះវានឹងរួមចំណែកដល់ការលើកកម្ពស់ឱ្យប្រសើរឡើងនូវចំណេះដឹងផ្នែកសុវត្ថិភាពចំណីអាហារ និងឥរិយាបថល្អក្នុងចំណោមអាជីវករលក់ដូរតាមដងផ្លូវនៅក្នុងប្រទេសកម្ពុជា។ ជាលទ្ធផល វានឹងពង្រឹងសុខភាពសាធារណៈ និងជំរុញការទាក់ទាញភ្ញៀវទេសចរណ៍នៅក្នុងប្រទេស។

**របកគំហើញចម្បងទី ៣៖** សម្លេងរួម និងអំណាចចរចារបស់(ស្ត្រី) អាជីវករលក់ដូរតាមដងផ្លូវនៅទន់ខ្សោយ និងមិនត្រូវបានរៀបចំឱ្យបានល្អ។ នេះជាលទ្ធផលនៃកង្វះការឯកភាព និង ការរួបរួមគ្នាបន្ថែមពីលើការរិតត្បិតលំហនយោបាយក្នុងរយៈពេល ៣ឆ្នាំកន្លងមកនេះ។ ទិន្នន័យបែបគុណភាពបង្ហាញថាមានអ្នកឆ្លើយ ៦៦.៣៩% ប៉ុណ្ណោះនៃអ្នកឆ្លើយសរុបគឺជាសមាជិកនៃសមាគម IDEA។ ហើយមានអ្នកឆ្លើយចំនួន ៤២.៦២% នៃអ្នកឆ្លើយសរុបចំនួន ៦៦.៣៩% ដែលជាសមាជិករបស់ IDEA បង្ហាញថាពួកគេមិនដឹងថាតើសមាគមនេះបានពង្រឹងអំណាច និងបានការពារផលប្រយោជន៍ពួកគេឬយ៉ាងណា។ នេះបង្ហាញថា វាតម្រូវឱ្យមានភាពជាតំណាង និងការផ្សព្វផ្សាយឱ្យបានខ្លាំងក្លាថែមទៀត។

**អនុសាសន៍ចម្បងទី ៣៖** សមាគម IDEA និងតួអង្គផ្សេងទៀតគួរពិចារណាអំពីការផ្សព្វផ្សាយជាសាធារណៈ និងការលើកទឹកចិត្តឱ្យកាន់តែខ្លាំងក្លាដើម្បីបង្កើនសមាជិកភាព និងការបង្កើតជាសហជីពសម្រាប់ (ស្ត្រី) អាជីវករលក់ដូរតាមដងផ្លូវ។ នេះវានឹងជួយបង្កើតនូវភាពជាតំណាង និងអំណាចចរចារួមឱ្យកាន់តែរឹងមាំ ដែលធ្វើឱ្យពួកគេមានសមត្ថភាពចរចា និងមានឥទ្ធិពលទៅលើថ្នាក់ដឹកនាំនយោបាយដើម្បីផលប្រយោជន៍របស់ពួកគេ។ ដោយសារ ធនធាន និងបុគ្គលិករបស់ IDEA នៅមានកម្រិត ការផ្សព្វផ្សាយជាសាធារណៈ និងការលើកទឹកចិត្តគួរផ្តោតលើ (ស្ត្រី) អាជីវករលក់ដូរតាមដងផ្លូវនៅក្នុងតំបន់ទីប្រជុំជនដែលកំពុងជួបបញ្ហាប្រឈមកាន់តែធ្ងន់ធ្ងរបើប្រៀបធៀបជាមួយអ្នកលក់ដូរដូចគ្នានៅស្រុកស្រែចម្ការ។

**របកគំហើញចម្បងទី ៤៖** កង្វះការការពារតាមផ្លូវច្បាប់ដល់ (ស្ត្រី) អាជីវករលក់ដូរតាមដងផ្លូវបណ្តាលឱ្យមានកង្វះទីកន្លែងលក់ដូរសមរម្យ និងការរំលោភបំពាន និងការកេងប្រវ័ញ្ចជាបន្តបន្ទាប់។ វាក៏មិនលើកទឹកចិត្តឱ្យអាជ្ញាធរធ្វើការឆ្លើយតបចំពោះបញ្ហាប្រឈម និងតម្រូវការ ដែលប្រឈមដោយ (ស្ត្រី) អាជីវករលក់ដូរតាមដងផ្លូវនៅទូទាំងប្រទេសកម្ពុជាផងដែរ។

**អនុសាសន៍ចម្បងទី ៤៖** រាជរដ្ឋាភិបាលកម្ពុជាគួរពិចារណាផ្តល់នូវកិច្ចការពារផ្លូវច្បាប់ដល់អាជីវករលក់ដូរតាមដងផ្លូវពីការរំលោភបំពាន និងការកេងប្រវ័ញ្ចជាលក្ខណៈប្រព័ន្ធ។ ហើយដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា ជាពិសេសគោលដៅទី ៨ (ការងារសមរម្យ & កំណើនសេដ្ឋកិច្ច) និងគោលដៅទី ១០ (កាត់បន្ថយវិសមភាព) វាចាំបាច់ថាអាជីវករលក់ដូរតាមដងផ្លូវទាំងនោះត្រូវបានគាំពារទាំងគោលនយោបាយ និងច្បាប់ការពារមួយ ដែលមានប្រយោជន៍ដល់ការពង្រឹងភាពធន់របស់ពួកគេ។

**របកគំហើញចម្បងទី ៥៖** ការយល់ដឹង និងចំណេះដឹងរបស់(ស្ត្រី)អាជីវករលក់ដូរតាមដងផ្លូវអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធជាមួយសិទ្ធិ និងសុខុមាលភាពរបស់ពួកគេនៅមានកម្រិត។ ទោះបីជាទិន្នន័យបង្ហាញថាមានអ្នកឆ្លើយសំណួរក្នុងសមាមាត្រយ៉ាងច្រើនឆ្លើយថាពួកគេបានរៀនសូត្រត្រឹមត្រូវក៏ប៉ុន្តែចំណេះដឹងអំពីច្បាប់ការពារសិទ្ធិ និងការប្រកបមុខរបរ ចិញ្ចឹមជីវិតរបស់ពួកគេនៅមានកម្រិត។ យោងតាមស្ថិតិបង្ហាញថា មានអ្នកឆ្លើយរហូតដល់ ៥២.៤៦% នៃអ្នកឆ្លើយសំណួរសរុបមិនបានដឹងអំពីច្បាប់បែបនោះឡើយ។ ហើយមានអ្នកឆ្លើយ ចំនួន ៥២.០៥% ឆ្លើយថាពួកគេមិនយល់អំពីខ្លឹមសារនៃរបបគាំពារសង្គម រួមទាំងសេចក្តីព្រាងច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈផងដែរ ដែលច្បាប់នេះបង្កឱ្យមានការទិះតៀនជាសាធារណៈ និងអាចគម្រាមកំហែងខ្លាំងដល់សិទ្ធិសេដ្ឋកិច្ចសង្គមរបស់ពួកគេ។ ប្រសិនបើច្បាប់នេះត្រូវបានអនុវត្ត ច្បាប់នេះនឹងដាក់បន្ទុកធ្ងន់ធ្ងរទៅលើ(ស្ត្រី)អាជីវករលក់ដូរតាមដងផ្លូវជាពុំខាន។

**អនុសាសន៍ចម្បងទី ៥៖** ក្រសួងមហាផ្ទៃគួរពិនិត្យមើលឡើងវិញនូវសេចក្តីព្រាងច្បាប់ស្តីពី**សណ្តាប់ធ្នាប់សាធារណៈ**នេះដើម្បីធានាថាច្បាប់នេះការពារផលប្រយោជន៍ និងពង្រឹងសិទ្ធិអំណាចរបស់ប្រជាពលរដ្ឋងាយរងគ្រោះបំផុត។ មានការស្នើសុំថាគួរមានការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ និងការផ្សព្វផ្សាយជាសាធារណៈដើម្បីកសាងជំនឿសាធារណៈជន ការគោរពគ្នាទៅវិញទៅមក និងធានានូវការចូលរួមដ៏សកម្មពី(ស្ត្រី)អាជីវករលក់ដូរតាមដងផ្លូវ ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចរបស់ប្រទេសជាតិ។ នេះវានឹងបង្ហាញដល់សាធារណៈជន និងសហគមន៍អន្តរជាតិ អំពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលនៃប្រទេសកម្ពុជាចំពោះការអភិវឌ្ឍសង្គមប្រកបដោយបរិយាប័ន្ន។

**របកគំហើញចម្បងទី ៦៖** មានកម្មវិធីជំនួយសង្គ្រោះបន្ទាន់ ដែលគាំទ្រដល់ក្រុមងាយរងគ្រោះ និងអ្នកដែលប៉ះពាល់ដោយជម្ងឺរាតត្បាតកូវីដ-១៩។ ទោះដូច្នេះក៏ដោយ អ្នកឆ្លើយសំណួរភាគច្រើនបំផុតបានឆ្លើយថាពួកគេមិនបានទទួលជំនួយគាំទ្រណាមួយនោះទេ។ ជំនួយសង្គ្រោះបន្ទាន់ទាំងនោះមានក្នុងទម្រង់ជាអំណោយស្បៀងអាហារ និងគ្រឿងទេសដែលវាមិនបានជួយដោះស្រាយបញ្ហាប្រឈមដែល (ស្ត្រី) អាជីវករលក់ដូរតាមដងផ្លូវទាំងអស់នោះបានជួបប្រទះឡើយ។ យោងតាមទិន្នន័យបែបគុណភាពបង្ហាញថាមានអ្នកឆ្លើយសំណួរចំនួន ៥៣% នៃអ្នកឆ្លើយសំណួរសរុបបានធ្វើចំណាកស្រុកចេញពីផ្ទះរបស់ពួកគេ។ ហើយដោយផ្អែកលើការសម្ភាស វាបង្ហាញថាការប្រឈមចម្បងរបស់អ្នកឆ្លើយសំណួរទាំងនោះគឺបញ្ហាបង់ពន្ធ/ភាស៊ី និងតម្លៃជួលកន្លែងលក់ដូរ ជាពិសេស ការជួលកន្លែងស្នាក់នៅប្រចាំខែរបស់ពួកគេជាជាងការទទួលបានស្បៀងអាហារ និងគ្រឿងទេសទៅទៀត។

**អនុសាសន៍ចម្បងទី ៦៖** រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសប្បុរសធម៌គួរពិចារណាពិនិត្យឡើងវិញនូវកម្មវិធីជំនួយសង្គ្រោះបន្ទាន់ចំពោះបញ្ហាកូវីដ -១៩ នេះ។ គេគួររៀបចំកម្មវិធីមួយដែលធ្វើឱ្យមានផលប៉ះពាល់ជាវិជ្ជមានរយៈពេលវែងជាជាងគ្រាន់តែផ្តល់ស្បៀង និងគ្រឿងទេស។ ដោយផ្អែកលើទិន្នន័យបែបគុណភាព ជំនួយសង្គ្រោះបន្ទាន់ដែលចាំបាច់សម្រាប់អាជីវករលក់ដូរតាមដងផ្លូវ គឺការលើកលែងការបង់ពន្ធ/ភាសុី និងកម្រៃការពារនានា រួមទាំងការឧបត្ថម្ភធនដ៏ច្រើនសម្រាប់គាំទ្រការបង់ថ្លៃជួលកន្លែងស្នាក់នៅរបស់ពួកគេ។

**របកគំហើញចម្បងទី ៧៖** ដោយផ្អែកលើទិន្នន័យបែបគុណភាពដែលទទួលបានពីការសម្ភាសអ្នកដឹងព័ត៌មានសំខាន់ៗ [N=២៤៤] វាច្បាស់ណាស់ថា សំណើធំៗទាំង ៣របស់អាជីវករលក់ដូរតាមដងផ្លូវក្នុងឆ្នាំ ២០២០ (កន្លែងថែទាំកុមារ ការលើកលែងការបង់ពន្ធ/ភាសុី និងថ្លៃឈ្នួល និងសិទ្ធិទទួលបានបណ្ណពណ៌លឿង ឬអត្ថប្រយោជន៍ពី ប.ស.ស) មិនត្រូវបានផ្តល់ជាអាទិភាព ឬត្រូវបានដោះស្រាយដោយរាជរដ្ឋាភិបាលកម្ពុជានៅឡើយ។ នេះបង្ហាញពី កង្វះការប្តេជ្ញាចិត្ត និង ការអូសទាញផ្នែកគោលនយោបាយពីស្ថាប័នរដ្ឋាភិបាលសំដៅទៅរកការលើកកម្ពស់ភាពធន់ និងសុខុមាលភាពរបស់(ស្ត្រី)អាជីវករលក់ដូរតាមដងផ្លូវ។

**អនុសាសន៍ចម្បងទី ៧៖** ដោយហេតុថាប្រជាជនកម្ពុជាចំណាយប្រាក់ចេញពីហៅប៉ៅរបស់ពួកគេសម្រាប់ការថែទាំសុខភាព ដែលមានចំនួនស្មើ ២/៣នៃការចំណាយប្រចាំគ្រួសារសរុប (Annear et al., ២០១៣, p. ២២៥), មានការស្នើថារាជរដ្ឋាភិបាលកម្ពុជាគួរពិនិត្យឡើងវិញ និងធ្វើការដោះស្រាយនូវសំណើធំៗទាំងនោះ។ ធ្វើបែបនេះវានឹងរួមចំណែកដល់ការលើកកម្ពស់សុខុមាលភាពផ្នែកសេដ្ឋកិច្ចរបស់ពួកគេ និងបង្ហាញពីការប្តេជ្ញាចិត្តដ៏រឹងមាំរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះសុខភាព និងសុខុមាលភាពល្អ សមភាពយេនឌ័រ និងការកាត់បន្ថយវិសមភាពដែលមានថែងជាបញ្ហាអាទិភាព នៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា។



**របកគំហើញចម្បងទី ៨៖** ការទទួលបានហិរញ្ញវត្ថុក្នុងចំណោមក្រុមងាយរងគ្រោះក្នុងប្រទេសកម្ពុជានៅតែជាបញ្ហាប្រឈមដ៏ធំនៅឡើយ។ តាមពិត មានការកើនឡើងគួរឱ្យកត់សម្គាល់នូវគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា បើប្រៀបធៀបទៅពីរទសវត្សរ៍មុន។ ទោះដូច្នេះក៏ដោយ ទំនាក់ទំនងរវាងការបំពេញតាមលក្ខខណ្ឌចាំបាច់ក្នុងការផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយគុណភាពខ្ពស់ និងការប្រាក់ទាប (financial efficiency) និងការយកចិត្តទុកដាក់ចំពោះរាល់ការចំណាយ និងអត្ថប្រយោជន៍ជាលក្ខណៈឯកជន និងសង្គម (social efficiency) នៅក្នុងប្រទេសកម្ពុជានៅតែជាកង្វល់សំខាន់ដដែល។ មានការសិក្សាមួយចំនួនលើកឡើងថាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជារកចំណេញបានច្រើនជាងការចំណាយរបស់ខ្លួនទៅទៀត។ និយាយម្យ៉ាងទៀត មិនមានការផ្សព្វផ្សាយជាលក្ខណៈសាកល ហើយ (ស្ត្រី) អាជីវករលក់ដូរតាមដងផ្លូវនៅតែមិនមានលទ្ធភាពទទួលបានហិរញ្ញវត្ថុ ដែលផ្តល់ឱ្យដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងនោះ។ ដូច្នេះ វារិតត្បិតសមត្ថភាពរបស់ពួកគេក្នុងការធ្វើវិនិយោគខ្នាតតូចនានា។

**អនុសាសន៍ចម្បងទី ៥៖** សមាជិកអង្គការ CSOs និងសហជីពគួរពិចារណាការវិភាជន៍ និងផ្តល់ប្រាក់កម្ចីគ្មានការប្រាក់ និងកម្ចីមានការប្រាក់ទាបដល់(ស្ត្រី)អាជីវករលក់ដូរតាមដងផ្លូវសម្រាប់ធ្វើវិនិយោគខ្នាតតូច។ ការមិនទទួលបានហិរញ្ញវត្ថុ ពិតជាបញ្ហាប្រឈមធំមួយសម្រាប់ (ស្ត្រី)អាជីវករលក់ដូរតាមដងផ្លូវក្នុងការដាក់ទុនវិនិយោគខ្នាតតូច ដូច្នេះវាធ្វើឱ្យប៉ះពាល់ដល់សក្តានុពលនៃវិស័យនេះ។ គេគួររៀបចំគំនិតផ្តួចផ្តើមនេះដើម្បីជម្រុញឱកាសមុខរបរ និងការងារ និងគំនិតច្នៃប្រឌិតចំពោះទំនិញ និងការផ្តល់សេវា។ ទាំងនេះវានឹងគាំទ្រដល់ស្ត្រីជាអ្នកលក់ដូរតាមដងផ្លូវទាំងនោះឱ្យអាចដោះស្រាយបាននូវបញ្ហានានាដែលបង្កឡើងដោយការរាតត្បាតនៃជម្ងឺកូវីដ -១៩។



# ១ សេចក្តីផ្តើម

ប្រទេសកម្ពុជាទទួលបានកំណត់ត្រាជាប្រទេសមានកំណើនសេដ្ឋកិច្ចខ្លាំងរយៈពេល១០ឆ្នាំកន្លងមកនេះបន្ទាប់ពីរួចផុតពីសង្គ្រាមស៊ីវិល និងរបបប្រល័យពូជសាសន៍រាប់ទស្សវត្សរ៍។ សន្ទស្សន៍អភិវឌ្ឍន៍មនុស្សរបស់ប្រទេសក៏មានការកើនឡើងល្អដែលរួមចំណែកដល់ភាពប្រកួតប្រជែងផ្នែកសេដ្ឋកិច្ចដ៏ខ្លាំង និងឱកាសបង្កើតមុខរបរ និងការងារ។ ប្រទេសកម្ពុជាក៏បានអនុវត្តបានយ៉ាងល្អបំផុតទាក់ទងជាមួយការកាត់បន្ថយភាពក្រីក្រ។ អត្រាភាពក្រីក្របានធ្លាក់ចុះពី ៤៧.៨% ក្នុងឆ្នាំ ២០០៧ មកតិចជាង ១៣.៥% ក្នុងឆ្នាំ ២០១៤ (ធនាគារពិភពលោក, ២០១៩)។ ប្រភពបឋមអំពីកំណើនសេដ្ឋកិច្ចបែបនោះមានអចលនទ្រព្យ និងសំណង់ កាត់ដេរសម្លៀកបំពាក់ និងឧស្សាហកម្មវាយនភណ្ឌ និងទេសចរណ៍ដែលជាក្បាលម៉ាស៊ីនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ចាប់តាំងពីក្រោយរបបប៉ុលពត។ មុនជម្ងឺកូវីដ -១៩ ប្រទេសកម្ពុជាមានកំណត់ត្រាទទួលបានវិនិយោគទុនដោយផ្ទាល់ពីបរទេស (FDI) ជាទឹកប្រាក់ចំនួន $៣.៥ ពាន់លានដុល្លា (Pisei, ២០១៩, p. ១), កើនឡើងចំនួន ១២% បើប្រៀបធៀបទៅឆ្នាំ ២០១៨។ តាមពិតការវិនិយោគទុនដោយផ្ទាល់ពីបរទេសនេះ បានធ្វើឱ្យរដ្ឋាភិបាលអាចបង្កើនថវិកាជាតិពី ៦ពាន់លានដុល្លាក្នុងឆ្នាំ ២០១៨ រហូតដល់ជាង $៦.៧ ពាន់លានដុល្លាក្នុងឆ្នាំ ២០១៩ (Meta, ២០១៩, p. ២), ដែលអនុញ្ញាតិឱ្យរដ្ឋាភិបាលអាចវិភាជន៍ថវិកាកាន់តែច្រើនទៅវិស័យសំខាន់ៗខ្លះដូចជាអប់រំ សុខភាពសាធារណៈ និងរបបគាំពារសង្គម។

ទោះបីជាមានសមិទ្ធិទាំងនេះក៏ដោយ ក៏ធនាគារពិភពលោក (២០១៧) កត់សម្គាល់ថា ប្រជាជនកម្ពុជានៅតែងាយរងគ្រោះពីបញ្ហាវិបត្តិសេដ្ឋកិច្ច (economic shock) និងព្រឹត្តិការណ៍សាកលលោក។ គេប៉ាន់ប្រមាណថាមានប្រជាជនកម្ពុជាចំនួន ៩០% នៃប្រជាជនសរុបរស់នៅទីជនបទ (ធនាគារពិភពលោក, ២០១៩) ដោយទទួលបានសេវាសាធារណៈបន្តិចបន្តួចបើប្រៀបធៀបជាមួយអ្នករស់នៅទីប្រជុំជន។ ហើយក្រៅពីមានកំណើនសេដ្ឋកិច្ចខ្ពស់គួរឱ្យស្ងើចសរសើរមក កសិកម្ម និងការធ្វើស្រែចម្ការនៅតែជាប្រភពចម្បងនៃការបង្កើតប្រាក់ចំណូលនៅក្នុងប្រទេស។ ការកើនឡើងនៃចំនួនពលរដ្ឋ មានន័យថាវាមានការលំបាកក្នុងការទទួលបានដីកសិកម្ម និងដីដាំដុះ ដូច្នេះហើយវាធ្វើឱ្យមានចំណាកស្រុកទៅកាន់ទីប្រជុំជន។ តាមកំណត់ត្រាឱ្យដឹងថា មានប្រជាពលរដ្ឋកម្ពុជាជាង ៤.១ លាននាក់បានធ្វើចំណាកស្រុកក្នុងប្រទេស ឬផ្លាស់ប្តូរទីកន្លែងស្នាក់នៅ (UNDP, ២០១៦, p. ២)។ តាមពិត ភាគច្រើននៃការធ្វើចំណាកស្រុកទៅកាន់ទីប្រជុំជន ជាពិសេស ចំពោះស្ត្រី និងយុវជន មានការកត់ត្រាច្បាស់លាស់នៅក្នុងឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និងវាយនភណ្ឌ បន្ទាប់មកនៅក្នុងវិស័យបដិសណ្ឋារកិច្ច និងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

ស្ត្រីកម្ពុជា នៅតែជាជនរងគ្រោះពីការរើសអើងក្នុងសង្គម និងបទដ្ឋានវប្បធម៌។ តួនាទីរបស់ពួកគេគឺការធ្វើការងារផ្ទះដោយមិនទទួលបានកម្រៃដូចជា មើលថែទាំកូន ចាស់ជរា និងគ្រួសារ។ ទោះបីជាស្ថានភាពស្ត្រីមានការកែលំអក៏ដោយក៏ស្ត្រីដែលរស់នៅតំបន់ជនបទភាគច្រើនធ្វើការនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដូចជា អ្នកប្រកបរបរកស៊ីតាមដងផ្លូវ។ ភស្តុតាងជាសាច់រឿងខ្លីៗ បង្ហាញថា អ្នកប្រកបរបរកស៊ីតាមដងផ្លូវនៅក្នុងប្រទេសកម្ពុជាមានចំនួន ១,៦៧៣,៣៩០ នាក់។ មានការប៉ាន់ប្រមាណថា អ្នកប្រកបរបរកស៊ីតាមដងផ្លូវនៅក្នុងទីក្រុងភ្នំពេញតែមួយមានចំនួន ១% នៃតួលេខទាំងនេះ ហើយ ៧៥% នៃពួកគេគឺជាស្ត្រី (Oxfam Cambodia, ២០១៩, p. ៧)។ តាមពិត ការលក់ដូរតាមដងផ្លូវដើរតួនាទីដ៏សំខាន់នៅក្នុងប្រព័ន្ធ អេកូឡូស៊ីពាណិជ្ជកម្មរបស់ក្រុង (Sekhani et al., ២០១៩) ដែលផ្តល់មុខរបរ និងការងារ និងប្រាក់ចំណូលដល់ប្រជាពលរដ្ឋដែលងាយរងគ្រោះតិចជាងគេបំផុត។ វិស័យនេះមានជិត ៩០% នៃអត្រាមុខរបរ និងការងារសរុប ហើយភាគច្រើនគឺជាស្ត្រី (អាស៊ាន, ២០១៩, p. ៤)។ ហើយទោះបីជាស្ត្រីមាន

ចំនួនជិត ៥២% នៃប្រជាពលរដ្ឋកម្ពុជាសរុប (ក្រសួងផែនការ, ២០១៩, p. ១៥) ការជួយគាំទ្រដែលអាចរកបានក្នុងទម្រង់ជាការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ច និងសង្គមសម្រាប់ពួកគេគឺពឹងផ្អែកខ្លាំងលើស្ត្រីម្នាក់ៗខ្លួនឯង និងសមាជិកនៃអង្គការ CSOs។ តាមពិត ការវិភាជន៍ថវិកាជាតិរបស់ក្រសួងកិច្ចការនារីមានចំនួនតិច បើប្រៀបធៀបទៅក្រសួងផ្សេងទៀតរបស់រដ្ឋាភិបាល។

ការសិក្សាវាយតម្លៃបឋមនេះ ត្រូវបានផ្តួចផ្តើមឡើងសម្រាប់ហេតុផលនេះ៖ ការពង្រឹងភាពអង់អាចរបស់ស្ត្រីផ្នែកសេដ្ឋកិច្ច និងសង្គមនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ វាជាផ្នែកមួយនៃគម្រោង "សកម្មភាពស្ត្រីសហគ្រិនកម្ពុជា (We Act) ដែលបានអនុវត្តដោយសម្ព័ន្ធដៃគូមានដូចជា វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) ជាបេក្ខជននាំមុខ និងសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA), និងសម្ព័ន្ធភាពសម្រាប់ភាពជាដៃគូនៅក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD) ជាសហបេក្ខជន។ គម្រោង We Act ទទួលមូលនិធិសប្បុរសធម៌ពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) តាមរយៈអង្គការ PACT Cambodia ដើម្បីធានាថា ស្ត្រីសហគ្រិនវ័យក្មេងត្រូវបានគេផ្តល់ឱកាសស្មើគ្នាទទួលបានសិទ្ធិសេដ្ឋកិច្ចសង្គមសមរម្យ និងរបបសន្តិសុខសង្គម ព័ត៌មានសាធារណៈ ឱកាសអប់រំ និងការទទួលបានការដោះស្រាយតាមផ្លូវច្បាប់ប្រកបដោយសមធម៌នៅក្នុងប្រទេសកម្ពុជា។

គម្រោង We Act គឺជាគម្រោងរយៈពេល ៥ឆ្នាំ ដែលផ្តោតលើស្ត្រីជាម្ចាស់សហគ្រិនមីក្រូ ធន់តូច និងមធ្យម (MSMEs) នៅក្នុងក្រុងបាត់ដំបង ភ្នំពេញ និងសៀមរាប។ គម្រោងនេះជាដំបូងត្រូវបានផ្តួចផ្តើមឡើងក្នុងឆ្នាំ ២០២០ ដើម្បីបង្កើតនូវមជ្ឈមណ្ឌលសម្របសម្រួលជាយុទ្ធសាស្ត្រមួយក្នុងចំណោមសមាជិកអង្គការ CSOs ដើម្បីគាំទ្រស្ត្រីសហគ្រិនវ័យក្មេងដែលមានសក្តានុពល។ គម្រោងនេះវាសមស្របគ្នាឥតខ្ចោះជាមួយយុទ្ធសាស្ត្រកម្មវិធីបឋមរបស់ API, IDEA, និង CPDD ដែលមានប្រវត្តិយូរលង់ និងបានប្រឹងប្រែងរួមគ្នាគាំទ្រដល់សហគមន៍ងាយរងគ្រោះ ជាពិសេស ក្រុមដឹកនាំដោយស្ត្រី និងយុវជននៅទូទាំងប្រទេសកម្ពុជា។ ឧទាហរណ៍ អង្គការដូចជាអង្គការ IDEA ត្រូវបានទទួលស្គាល់ថាជាអង្គការនាំមុខក្នុងការងារតស៊ូមតិដើម្បីបានលក្ខខណ្ឌការងារសមរម្យ និងការគាំពារសង្គមដល់សមាជិករបស់ខ្លួនរាប់ម៉ឺននាក់ដែលភាគច្រើនធ្វើការនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA, ២០២១)។



## ២ សនិទានភាពនៃការសិក្សាវាយតម្លៃ

ការរាតត្បាតនៃជម្ងឺកូវីដ-១៩ បានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់មនុស្សជាច្រើននៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជាពិសេស ស្ត្រីលក់ដូរតាមដងផ្លូវដែលបានទទួលអត្ថប្រយោជន៍បន្តិចបន្តួច ឬមិនបានទទួលសោះពីកម្មវិធីគាំទ្ររបស់រដ្ឋាភិបាល។ ទាំងនេះវាបានគម្រាមកំហែងក្នុងកម្រិតជាក់លាក់មួយដល់ការប្រកបរបរចិញ្ចឹមជីវិត និងភាពធន់របស់អ្នកប្រកបរបរកស៊ីតាមដងផ្លូវដែលងាយរងគ្រោះជាច្រើននាក់ រួមទាំងសមាជិកគ្រួសារ និងការអប់រំកូនៗរបស់ពួកគេដែលអ្នកទាំងនោះបាន និងកំពុងប្រឹងប្រែងតស៊ូរួចមកហើយជាមួយស្ថានភាពរស់នៅដ៏លំបាករបស់ពួកគេ។ ដោយផ្អែកលើកត្តាទាំងអស់នេះ គោលបំណងនៃការសិក្សាវាយតម្លៃបឋមនេះមាន៖ ក) ធ្វើការវាយតម្លៃផលប៉ះពាល់ពីការរាតត្បាតជម្ងឺកូវីដ-១៩ ទៅលើស្ថានភាពសេដ្ឋកិច្ចសង្គម និងស្ថានភាពរស់នៅរបស់ស្ត្រីលក់ដូរតាមដងផ្លូវនៅក្នុងប្រទេសកម្ពុជា ខ) ធ្វើការសិក្សាអំពីការឆ្លើយតបផ្នែកគោលនយោបាយ ចំពោះផលប៉ះពាល់ទាំងនោះពីខាង រដ្ឋាភិបាលកម្ពុជា អង្គការ NGOs និងភាគីពាក់ព័ន្ធផ្សេងទៀតដែលធ្វើការក្នុងវិស័យនេះ និង គ) ដើម្បីស្វែងយល់អំពីការឆ្លើយតបបែបអន្តរកម្មផ្នែកគោលនយោបាយ និងបញ្ហាទាំងឡាយនៅក្នុងកិច្ចការគាំពារសង្គម និងការងារ។ យើងជឿជាក់ថាការសិក្សានេះនឹងរួមចំណែកដល់ការធ្វើអន្តរាគមន៍ផ្នែកគោលនយោបាយដ៏មានប្រសិទ្ធិភាពពីរដ្ឋាភិបាលដៃគូអភិវឌ្ឍន៍ និងតួអង្គផ្សេងទៀត។

## ៣ វិធីសាស្ត្រ

វិធីសាស្ត្របែបគុណភាពត្រូវបានប្រើប្រាស់នៅក្នុងការសិក្សាវាយតម្លៃនេះ។ វិធីសាស្ត្រនេះផ្តល់ដល់យើងនូវឱកាសដើម្បីស្វែងយល់ និងប្រមូលទស្សនៈ និងបញ្ហាប្រឈមទាំងឡាយរបស់អ្នកឆ្លើយសំណួរជាក្រុមគោលដៅបន្ថែមទៅលើទិន្នន័យជាតួលេខ។ មានអ្នកឆ្លើយសំណួរជាក្រុមគោលដៅចំនួន ២៤៤ នាក់នៅក្នុងខេត្តចំនួន ៣ ដែលត្រូវបានសម្ភាសដែលអនុញ្ញាតិឱ្យយើងអាចបង្កើតបានជាទិន្នន័យបែបគុណភាព។ បន្ថែមពីលើនេះការសិក្សាដែលមានស្រាប់ គោលនយោបាយរបស់រដ្ឋាភិបាល ឯកសារស្រាវជ្រាវ របាយការណ៍ និងអត្ថបទព្រឹត្តិប័ត្រនានាត្រូវបានពិនិត្យឡើងវិញដើម្បីកំណត់ និងស្វែងរកឱ្យឃើញអំពីបញ្ហាប្រឈម និងផលវិបាកផ្នែកផ្លូវច្បាប់នានា រួមទាំងអន្តរាគមន៍ផ្នែកគោលនយោបាយសំខាន់ៗដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះ។

### ៣.១. បទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ

ការសម្ភាសអ្នកដឹងព័ត៌មានសំខាន់ៗ (KII) ត្រូវបានធ្វើឡើងជាមួយស្ត្រីគោលដៅជាអាជីវករលក់ដូរតាមដងផ្លូវចំនួន ២៤៤ នាក់ [N=២៤៤] ដើម្បីធ្វើការវាយតម្លៃឱ្យកាន់តែល្អប្រសើរអំពីបញ្ហាប្រឈមដែលពួកគេកំពុងជួបប្រទះ និងផលប៉ះពាល់បណ្តាលមកពីជម្ងឺកូវីដ -១៩ និងលទ្ធផលរបស់វា។ ការសម្ភាសនេះក៏មានគោលបំណងស្វែងយល់អំពីតម្រូវការរបស់ពួកគេ ហើយក្រោយមកបញ្ចូលការវិភាគទិន្នន័យបែបគុណភាពទាំងនេះ ទៅក្នុងអនុសាសន៍ផ្នែក គោលនយោបាយ។ ក្រុមប្រមូលទិន្នន័យត្រូវបានពន្យល់ប្រាប់ខ្លីៗ ហើយត្រូវគោរពតាមយ៉ាងខ្ជាប់ខ្ជួននូវការរក្សាឯកជនភាពបុគ្គល និងបទដ្ឋានក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ។ សំណួរសម្រាប់ប្រមូលទិន្នន័យជាច្រើន (សូមអានឧបសម្ព័ន្ធ) ត្រូវបានរៀបចំឡើង និងធ្វើការ សាកល្បងដោយសមាជិកក្រុមប្រមូលទិន្នន័យមុនពួកគេចុះទៅធ្វើ KII។

KII [N=២៤៤] ត្រូវបានអនុវត្តដោយជោគជ័យជាមួយអ្នកឆ្លើយសំណួរជាក្រុមគោលដៅនៅក្នុងក្រុងបាត់ដំបងនៅថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០២១។ ទោះដូច្នេះក្តី KII [N=២៤៤] ក្នុងក្រុងភ្នំពេញ និងសៀមរាប ត្រូវបានពន្យាពេលបន្ទាប់ពីមានការឆ្លងកូវីដ-១៩នៅក្នុងសហគមន៍ និងការរឹតត្បិតមិនឱ្យមានការជួបជុំជាសាធារណៈរបស់រដ្ឋាភិបាល។ បន្ទាប់មកមានការជំនួសដោយការ ធ្វើសម្ភាសតាមទូរស័ព្ទដោយប្រើប្រាស់វិធីសាស្រ្តព្រិលបាល់ចាប់ពីថ្ងៃទី ៩ រហូតដល់ថ្ងៃទី ២៤ខែមីនា ឆ្នាំ ២០២១។ ដំណើរការនេះត្រូវបានអនុវត្តដោយមានជំនួយពីបុគ្គលិក API, IDEA, និង CPDD។ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការធ្វើការងារនេះដោយជោគជ័យ។ បន្ទាប់មកទិន្នន័យត្រូវបានធ្វើប្រតិចារិក និងស្រង់យកមកធ្វើវិភាគ។ អនុសាសន៍ផ្នែកគោលនយោបាយនេះ ឆ្លុះបញ្ចាំងអំពីទស្សនៈចម្បងៗ និងបង្ហាញទិន្នន័យបែបគុណភាព។

### ៣.២. ការប្រឹក្សាយោបល់

ការពិគ្រោះយោបល់តាមអនឡាញអំពីលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ ត្រូវបានរៀបចំ និងចូលរួមដោយតំណាងស្ត្រីលក់ដូរតាមដងផ្លូវ សមាជិករបស់ IDEA និងសមាជិកអង្គការ CSOs។ សិក្ខាសាលាពិគ្រោះយោបល់តាមអនឡាញក្នុងក្រុងសៀមរាប ត្រូវបានធ្វើឡើងនៅថ្ងៃទី ១៣ ខែឧសភា ឆ្នាំ ២០២១ និងមានការចូលរួមពីអ្នកចូលរួមចំនួន ២២នាក់ (ស្រី ១០ នាក់)។ សិក្ខាសាលានៅក្រុងបាត់ដំបងត្រូវបានរៀបចំនៅថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០២១ និងមានការចូលរួមពីអ្នកចូលរួមចំនួន ២៣ នាក់ (ស្រី ១៥ នាក់) បន្ទាប់មកមានសិក្ខាសាលាពិគ្រោះយោបល់តាមអនឡាញមួយទៀតនៅក្នុងទីក្រុងភ្នំពេញនៅថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០២១ ដែលមានការចូលរួមពីអ្នកចូលរួមចំនួន ២០ នាក់ (ស្រី ១៥ នាក់)។ លទ្ធផលដែលបានរកឃើញត្រូវបានយកទៅពិគ្រោះយោបល់ជាមួយពួកគេ និងផ្តល់ឱកាសដល់ពួកគេឱ្យផ្តល់យោបល់ត្រឡប់ និងមតិយោបល់របស់ពួកគេ ដែលក្រោយមកត្រូវបានពិនិត្យ និងបញ្ចូលទៅក្នុងអនុសាសន៍ចម្បងៗ។

### ៣.៣. អ្នកឆ្លើយតបគោលដៅ និងលំនៅដ្ឋានរបស់អ្នកឆ្លើយតប

មានស្ត្រីលក់ដូរតាមដងផ្លូវចំនួន ២៤៤ នាក់ត្រូវបានសម្ភាស និងជ្រើសរើសដោយផ្អែកលើទីតាំងភូមិសាស្ត្ររបស់ពួកគេ។ មានការជឿជាក់ថាការបែងចែកអ្នកឆ្លើយសំណួរពិតជាមានសារៈសំខាន់ណាស់ហើយគួរបង្ហាញចំនួនពួកគេនៅក្នុងតំបន់គោលដៅនីមួយៗ។ ដោយធ្វើបែបនេះ ការបែងចែកប្រជាសាស្ត្រនៃអ្នកឆ្លើយតបមានគោលបំណងធ្វើការវាយតម្លៃបញ្ហាប្រឈមនាពេលបច្ចុប្បន្ន និងបទពិសោធន៍រស់នៅរបស់ស្ត្រីលក់ដូរតាមដងផ្លូវហើយទន្ទឹមនោះធ្វើការប្រមូលទស្សនៈរបស់ពួកគេ ចំពោះការឆ្លើយតបរបស់រដ្ឋាភិបាលចំពោះការរាតត្បាតជម្ងឺកូវីដ-១៩។ អ្នកឆ្លើយតបជាគោលដៅ និងលំនៅដ្ឋានរបស់ពួកគេត្រូវបានកត់ត្រាដូចខាងក្រោម៖

| តំបន់គោលដៅ | អ្នកឆ្លើយតបគោលដៅ | សរុប |
|---|---|---|
| ភ្នំពេញ | ស្ត្រីលក់ដូរតាមដងផ្លូវចំនួន ១៤៤នាក់ | ១៤៤ |
| បាត់ដំបង | ស្ត្រីលក់ដូរតាមដងផ្លូវចំនួន ៥០ នាក់ | ៥០ |
| សៀមរាប | ស្ត្រីលក់ដូរតាមដងផ្លូវចំនួន ៥០នាក់ | ៥០ |
| សរុប | | ២៤៤ |

## ៤ ក្រមសីលធម៌បទសម្ភាសន៍

កម្រិតអប់រំរបស់ស្ត្រីជាអ្នកលក់ដូរតាមដងផ្លូវមានកម្រិតទាបបើប្រៀបធៀបជាមួយបុរសជាអាជីវករលក់ដូរតាមដងផ្លូវ។ នេះគឺជាលទ្ធផលនៃសង្គ្រាម និងរបបប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជាក្នុងទសវត្សរ៍ឆ្នាំ ៧០ ដែលធ្វើឱ្យវាមានការលំបាកដោយមិនបានអានសំណួរប្រមូលទិន្នន័យក្នុងអំឡុងពេលធ្វើសម្ភាស។ ម្យ៉ាងទៀតមានការភ័យខ្លាចការកត់ឈ្មោះ និងថតសម្លេងដែលបញ្ហានេះមិនមែនជារឿងធម្មតានៅក្នុងប្រទេសកម្ពុជាឡើយ។ ដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងនេះ អ្នកសម្ភាសត្រូវអានគោលបំណងនៃការសិក្សាដែលមាននៅលើក្រដាសព័ត៌មាន រួចស្នើសុំការព្រមព្រៀងផ្ទាល់មាត់របស់ពួកគេមុនចាប់ផ្តើមសម្ភាស។ ឈ្មោះ និងសម្លេងរបស់ពួកគេមិនត្រូវបានកត់ត្រា និងថតទុកនោះទេ។ អ្នកឆ្លើយសំណួរដែលជាគោលដៅនៃការសម្ភាស ត្រូវបានជម្រាបឱ្យមានការទុកចិត្តថានៅក្នុងការប្រមូលទិន្នន័យនេះមិនមានការប្រើប្រាស់ឈ្មោះរបស់ពួកគេនោះទេ ហើយចម្លើយរបស់ពួកគេនឹងត្រូវយកទៅបូកសរុបជាមួយចម្លើយអ្នកឆ្លើយសំណួរផ្សេងទៀត។ អ្នកឆ្លើយសំណួរត្រូវបានប្រាប់អំពីសិទ្ធិមិនឆ្លើយចំពោះសំណួរណាមួយ ឬធ្វើការចាកចេញពីការសម្ភាសតាមចិត្តចង់របស់ពួកគេ។

## ៥ ដែនកំណត់នៃការសិក្សាវាយតម្លៃ

ការសិក្សាវាយតម្លៃបឋមនេះ ផ្តោតតែលើបញ្ហាប្រឈមនាពេលបច្ចុប្បន្ន និងផលប៉ះពាល់ពីជំងឺរាតត្បាតកូវីដ-១៩ ទៅលើស្ត្រីលក់ដូរតាមដងផ្លូវចាប់ពីដើមឆ្នាំ ២០២០ រហូតដល់ខែមីនា ឆ្នាំ ២០២១ តែប៉ុណ្ណោះ ដោយរួមបញ្ចូលទាំងការឆ្លើយតបផ្នែកគោលនយោបាយរបស់ រដ្ឋាភិបាលនៅក្នុងរយៈពេលដូចគ្នានេះ។ ឧទាហរណ៍ យើងមិនអាចសម្ភាស និងធ្វើការវាយតម្លៃអំពីទស្សនៈយល់ឃើញរបស់ស្ថាប័នរដ្ឋាភិបាល ក្រុមសិទ្ធិមនុស្ស និងអង្គការការងារ រួមទាំងសាធារណៈជនទូទៅចំពោះស្ត្រីលក់ដូរតាមដងផ្លូវនៅក្នុងព្រះរាជាណាចក្រកម្ពុជានោះទេ។

ការផ្ទុះជម្ងឺកូវីដ-១៩ នៅក្នុងសហគមន៍នៅចុងខែកុម្ភៈ ឆ្នាំ ២០២១ បង្កឱ្យមានបញ្ហាប្រឈម ខ្លាំងដល់ការសិក្សានេះ។ ការប្រមូលផ្តុំសាធារណៈជនត្រូវបានរិតត្បិត ហើយយើងក៏មិនអាចរៀបចំការសម្ភាសនៅក្នុងទីក្រុងភ្នំពេញ និងសៀមរាបបានផងដែរ។ ដំណើរការនេះត្រូវបានជំនួសដោយការសម្ភាសតាមទូរស័ព្ទដែលត្រូវចំណាយពេលវេលា និងការប្រឹងប្រែងយ៉ាងច្រើនដើម្បីសម្ភាសអ្នកជាក្រុមគោលដៅទាំងនោះ។ ទាំងនេះគឺជាកង្វះខាតនៃឯកសារសិក្សាស្រាវជ្រាវនេះ។



# ៦ ប្រជាសាស្ត្រនៃអ្នកឆ្លើយតប

ដូចប្រជាជាតិដទៃទៀតដែរ ការធ្វើចំណាកស្រុកបានចាប់ឫសគល់នៅក្នុងសង្គមកម្ពុជារាប់សតវត្សមកហើយ។ ការសិក្សាផ្សេងទៀតកត់សម្គាល់ថាប្រជាពលរដ្ឋកម្ពុជាជាអ្នកចូលចិត្តធ្វើបន្លាស់ទីច្រើន (Lawreniuk & Parsons, ២០១៧; Parsons, ២០១៦)។ ទិន្នន័យបែបគុណភាពពីការសិក្សាវាយតម្លៃនេះ បញ្ជាក់ថាការលើកឡើងនេះគឺជាការត្រឹមត្រូវ។ តាមការប៉ាន់ប្រមាណអ្នកឆ្លើយសំណួរចំនួន ៥៣% នៃអ្នកឆ្លើយសំណួរសរុបបានធ្វើចំណាកស្រុកមករស់នៅលំនៅដ្ឋាននាពេលបច្ចុប្បន្នរបស់ពួកគេ។ សំខាន់ជាងនេះទៀតមានកត្តាផ្សេងៗដែលរួមចំណែកយ៉ាងច្រើនដល់លំនាំនៃការធ្វើចំណាកស្រុកថ្មីៗនេះនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ កង្វះដីធ្លីប្រើប្រាស់ ការមិនមានឱកាសបង្កើតមុខរបរ និងការងារ រួមទាំងការប៉ះពាល់ជាប្រចាំពីការប្រែប្រួលអាកាសធាតុ គឺជាកត្តាចម្បងនៃការធ្វើចំណាកស្រុកនៅក្នុងប្រទេសកម្ពុជា (មូលនិធិអាស៊ី, ២០១១; កម្មវិធីស្បៀងអាហារពិភពលោក, ២០១៩)។ ហើយវាសំខាន់ដែលត្រូវកត់សម្គាល់ថា ប្រជាសាស្ត្រវ័យក្មេងរបស់ប្រទេសដាក់សម្ពាធយ៉ាងធ្ងន់ទៅលើសេដ្ឋកិច្ចដ៏ក្មេងខ្ចីរបស់ខ្លួន។ តាមការប៉ាន់ប្រមាណ មានប្រជាពលរដ្ឋចំនួន ៥០% នៃចំនួនប្រជាពលរដ្ឋសរុបមានអាយុក្រោម ២២ ឆ្នាំ (វិទ្យាស្ថានជាតិស្ថិតិ, ២០១៩), ហើយក្នុងចំណោមប្រជាពលរដ្ឋពី ២៥០,០០០ ទៅ ៣០០,០០០នាក់ នៃពួកគេពេញកម្លាំងចូលធ្វើការងារក្នុង ១ឆ្នាំៗ (អង្គការការងារអន្តរជាតិ, ២០១៥)។ កត្តាទាំងនេះវាជម្រុញឱ្យមានការធ្វើចំណាកស្រុកកាន់តែច្រើនឡើងនៅក្នុងប្រទេសកម្ពុជានាពេលថ្មីៗនេះ។




*រូបទី ១. លំនៅដ្ឋានរបស់អ្នកឆ្លើយសំណួរ*

ស្ត្រីលក់ដូរតាមដងផ្លូវមានវ័យក្មេង និងបានរៀនសូត្របានត្រឹមត្រូវ។ ទិន្នន័យបង្ហាញថាមានអ្នកឆ្លើយសំណួរចំនួន ៤៣.៨៥% នៃអ្នកឆ្លើយសរុបមានអាយុចន្លោះ ២៦-៣៥ ឆ្នាំ បន្ទាប់មកចំនួន ២៩.១០% គឺអ្នកមានអាយុចន្លោះ ៣៦-៤៥ ឆ្នាំ។ អ្នកដែលមានអាយុចន្លោះ ១៨-២៥ឆ្នាំមានចំនួន ៦.៩៧% នៃអ្នកឆ្លើយសរុប និង ៥.៧៤% នៃអ្នកទាំងនោះមានអាយុចន្លោះ ៥៦-៦៥ឆ្នាំ។ គួរឱ្យភ្ញាក់ផ្អើលដែលមានចំនួនច្រើនជាង ៧៧% នៃអ្នកឆ្លើយសំណួរបានរៀនសូត្រត្រឹមត្រូវ។ អ្នកដែលបានរៀននៅបឋមសិក្សាមានចំនួន ៤៥.៤៩%, បន្ទាប់មកមាន ២៣.៧៧% បានរៀននៅអនុវិទ្យាល័យ ហើយ ៧.៧៩% នៃអ្នកឆ្លើយសំណួរសរុបបានរៀននៅវិទ្យាល័យ។ ទោះដូច្នេះក្តី ទិន្នន័យបង្ហាញថាមាន ២២.៥៤% នៃពួកគេមិនដែលបានចូលរៀនសោះ។ លទ្ធផលទាំងនេះអាចធ្វើការប្រៀបធៀបបានជាមួយលទ្ធផល ដែលទទួលបានពីអង្កេតតាមអនឡាញដែលធ្វើឡើងដោយ API ក្នុងឆ្នាំ ២០២០ ដែលរកឃើញសមាមាត្រដ៏ច្រើននៃអ្នកឆ្លើយសំណួរបានរៀនសូត្រត្រឹមត្រូវ។




*រូបទី ២. អាយុ និងកម្រិតអប់រំរបស់អ្នកឆ្លើយសំណួរ*

# ៧ លទ្ធផលរកឃើញសំខាន់ៗ

ទំព័រខាងក្រោមៗ មានពិភាក្សាលំអិតអំពីរបកគំហើញចម្បងៗនៃការសិក្សាវាយតម្លៃនេះ។ តួលេខទាំងនេះឆ្លុះបញ្ចាំងអំពីទស្សនៈ និងបញ្ហាប្រឈមដែលប្រមូលបានពីអ្នកឆ្លើយសំណួរជាក្រុមគោលដៅសរុបចំនួន ២៤៤ នាក់នៅក្នុងក្រុងបាត់ដំបង ភ្នំពេញ និងសៀមរាប។

## ៧.១. ទីកន្លែងលក់ដូរ និងការកេងប្រវ័ញ្ច

ទិន្នន័យពីការសិក្សាវាយតម្លៃបង្ហាញពីទម្លាប់លក់ដូរ និងលំនាំនៃការលក់ដូរដ៏គួរឱ្យចាប់អារម្មណ៍។ មានអ្នកឆ្លើយសំណួរសរុបចំនួន ៤០.៥៧% បញ្ជាក់ថាពួកគេបានប្រកបរបរលក់ដូរនេះរវាងពី ១-៣ ឆ្នាំ ហើយ ៣៥.៨% នៃអ្នកទាំងនោះបានប្រកបរបរលក់ដូរចន្លោះ ៤-៥ ឆ្នាំ។ អ្នកដែលប្រកបរបរលក់ដូរច្រើនជាង ៦ ឆ្នាំមានប្រហែល ២១.៧២% នៃអ្នកឆ្លើយសំណួរសរុប។ តួលេខដ៏គួរឱ្យចាប់អារម្មណ៍មួយទៀតគឺទាក់ទងនឹងទីកន្លែងលក់ដូររបស់ពួកគេ។ ទិន្នន័យបង្ហាញថាមាន ៤៩.៥៩% នៃពួកគេកំពុងលក់ដូរនៅតាមដងផ្លូវ ខណៈ ១៨.៤៤% នៃអ្នកឆ្លើយសំណួរសរុបជាអ្នកលក់ដូរចល័ត និងមានជិត ១៣.៩៣% នៃអ្នកទាំងនោះមានទីកន្លែងលក់ដូរនៅក្នុងផ្សារ។ នេះបង្ហាញពីសមាសភាពចម្រុះខ្លាំងរបស់អាជីវករលក់ដូរតាមដងផ្លូវនៅក្នុងព្រះរាជាណាចក្រកម្ពុជា។




*រូបទី ៣ & ៤. ឆ្នាំនៃការលក់ដូរ និងទីកន្លែងលក់ដូរ*

តម្រូវការកើនឡើងរកកន្លែងលក់ដូរ បាននាំទៅរកអំពើកេងប្រវ័ញ្ចជាប្រព័ន្ធមកលើ (ស្ត្រី)អាជីវករលក់ដូរតាមដងផ្លូវនៅទូទាំងប្រទេសកម្ពុជា។ ដោយការបង់ប្រាក់ក្រោមតុនៅតែជាបញ្ហាប្រឈមនៅក្នុងប្រទេស និងកង្វះកិច្ចការពារផ្លូវច្បាប់ ស្ត្រីជាអ្នកលក់ដូរតាមដងផ្លូវងាយរងគ្រោះពីអំពើកេងប្រវ័ញ្ចដែលមានលក្ខណៈជាប្រព័ន្ធនេះខ្លាំងណាស់។ ការសិក្សាវាយតម្លៃបានរកឃើញនូវតួលេខអំពីការចំណាយរបស់ពួកគេជាការប្តូរយកកន្លែងលក់ដូរ និងកិច្ចការពារប្រចាំថ្ងៃដ៏គួរឱ្យខ្លោចចិត្ត។ ទិន្នន័យបង្ហាញថាមាន ៤៩.៥៩% នៃអ្នកឆ្លើយសំណួរសរុបបានបង់ថ្លៃដល់សន្តិសុខផ្សារ និងមាន ២៩.៥១% នៃអ្នកឆ្លើយសំណួរបានគូសបញ្ជាក់ថាពួកគេបានបង់ប្រាក់ដល់បុគ្គលមិនស្គាល់អត្តសញ្ញាណ និងបុគ្គលដែលមានឯកសណ្ឋានធម្មតា។ តាមការប៉ាន់ប្រមាណមាន១៨.៨៥% នៃអ្នកឆ្លើយសំណួរបានបញ្ជាក់ថាពួកគេបានបង់ប្រាក់ទៅនគរបាលនៅមូលដ្ឋានជាថ្នូរទទួលបានកន្លែងលក់ដូរ និងការការពារ។ ចំនួននៃការបង់ប្រាក់បែបនេះអាចបកស្រាយបានថា នេះគឺជាក្រុមជំនួញធ្វើមានធ្វើបានក្នុងចំណោមក្រុមនគរបាលពុករលួយ។ គួរឱ្យភ្ញាក់ផ្អើល ទិន្នន័យបង្ហាញថា ៥៤.១០% នៃអ្នកឆ្លើយសំណួរសរុបបង់ប្រាក់ចន្លោះ៥០០-១,០០០ រៀលជាមធ្យមជារៀងរាល់ថ្ងៃ និង ២៩.៥២% បង់ប្រាក់រវាងពី ១,១០០-២,០០០ រៀលជាមធ្យមក្នុងមួយថ្ងៃ។ តួលេខទាំងនេះបង្ហាញពីការកេងប្រវ័ញ្ចឥតឈប់ឈរពីលើស្ថានភាពរស់នៅដ៏ខ្សត់ខ្សោយរួចទៅហើយ ដែលស្ត្រីលក់ដូរតាមដងផ្លូវកំពុងប្រឈមជារៀងរាល់ថ្ងៃ។




*រូបទី ៥ & ៦. ថ្លៃការពារជាមធ្យមក្នុង១ថ្ងៃ និងអ្នកប្រមូល*

កង្វះការការពារផ្លូវច្បាប់ចំពោះអាជីវករលក់ដូរតាមដងផ្លូវនៅក្នុងប្រទេសកម្ពុជា បង្កើតឱ្យមានការរំលោភបំពាន និងការកេងប្រវ័ញ្ចជាប្រព័ន្ធមកលើពួកគេ។ ហើយចំពោះអ្នកដែលបដិសេធមិនគោរពតាមគេ និងត្រូវគេផ្តល់នូវមេរៀនដ៏ជូរចត់មួយ ឬពីរ។ ការសិក្សារបស់ Agnello និង Moller (មាននៅក្នុង Kyoko, ២០០៦) បានរកឃើញពីការធ្វើទុកបុកម្នេញជាប្រព័ន្ធមកលើអាជីវករលក់ដូរតាមដងផ្លូវ។ ហើយភាគច្រើននៃអ្នកឆ្លើយសំណួរបានរអ៊ូរទាំខ្លាំងៗចំពោះសន្តិសុខផ្សារ និងនគរបាល។ ទោះបីជាមិនមានភស្តុតាងបែបស្ថិតិថ្មីៗនេះដើម្បីបញ្ជាក់ នូវការអះអាងបែបនេះក៏ដោយ ក៏ការធ្វើទុក្ខបុកម្នេញមកលើអាជីវករលក់ដូរតាមដងផ្លូវនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ជាញឹកញាប់ត្រូវបានគេផ្សព្វផ្សាយនៅលើបណ្តាញផ្សព្វផ្សាយ(សង្គម)។ កាលពីប៉ុន្មានឆ្នាំមុន ប្រធានមណ្ឌលសុខភាពម្នាក់នៅខណ្ឌចំការមន និងបក្ខពួករបស់គាត់ត្រូវបានគេរាយការណ៍មកថា បានទារប្រាក់ប្រចាំខែចំនួន $៩០ ពីអ្នកលក់ចំណីអាហារនៅតាមដងផ្លូវនៅជុំវិញមណ្ឌល (Meta, ២០១៧)។ ហេតុការណ៍មួយទៀតបានកើតឡើងនៅក្នុងខែមីនា ឆ្នាំ ២០២១ នៅក្នុងខេត្តព្រះសីហនុក៏បានធ្វើឱ្យមានការតវ៉ាពីសាធារណៈជនផងដែរ។ មានសេចក្តីរាយការណ៍ថាសន្តិសុខបានទារភាស៊ីលើសចំនួនពីស្ត្រីលក់ដូរតាមដងផ្លូវម្នាក់ ហើយក្រោយមកបានកំទេចទំនិញរបស់គាត់បន្ទាប់ពីមានការប្រកែកតវ៉ាគ្នាដ៏ក្តៅគគុករួចមក (Voun, ២០២១)។ ទាំងនេះមិនមែនជាហេតុការណ៍ដាច់ដោយឡែកឡើយហើយការមិនមានការទទួលស្គាល់តាមផ្លូវច្បាប់ មានន័យថាអាជីវករលក់ដូរតាមដងផ្លូវនៅតែងាយរងគ្រោះពីការរំលោភបំពាន និងការកេងប្រវ័ញ្ចឥតឈប់ឈរដដែល។

## ៧.២. សុវត្ថិភាពចំណីអាហារ និងឥរិយាបថរបស់អាជីវករលក់ដូរតាមដងផ្លូវ

សុវត្ថិភាពចំណីអាហាររបស់អាជីវករលក់ដូរតាមដងផ្លូវ នៅក្នុងប្រទេសកម្ពុជានៅតែជា ប្រធានបទដដែលពិភាក្សាមួយនៅឡើយ។ ហើយមកដល់ពេលនេះមានការបោះពុម្ពផ្សាយបន្តិចបន្តួចអំពីសុវត្ថិភាពចំណីអាហារ និងឥរិយាបថរបស់អាជីវករលក់ដូរតាមដងផ្លូវ។ លើសពីនេះ សុវត្ថិភាពចំណីអាហារបានក្លាយជាចំណាប់អារម្មណ៍សម្រាប់ធ្វើការសិក្សាស្រាវជ្រាវនៅក្នុងសង្គមឧស្សាហកម្ម។ ហើយមានប្រទេសខ្លះបានចាត់ទុកវាថាជាបញ្ហាសន្តិសុខជាតិរបស់ប្រទេសថែមទៀតផង (Ma et al., ២០១៩)។ ការលក់ដូរតាមចញ្ចើមផ្លូវនៅក្នុងប្រទេសកម្ពុជាពិតជានឹងបង្កការគម្រាមកំហែងដល់សុខភាពសាធារណៈនៅពេលអនាគតមែន ប្រសិនបើមិនមានការផ្សព្វផ្សាយដល់សហគមន៍ និងការធ្វើអន្តរាគមន៍ផ្នែកគោលនយោបាយទេនោះ។ លទ្ធផលនៃការសិក្សាស្រាវជ្រាវបង្ហាញថា ចំណីអាហារតាមផ្លូវគឺជាប្រភពចម្បងនៃបញ្ហាសុវត្ថិភាពចំណីអាហារនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន។ ចំណីអាហារតាមផ្លូវនៅប្រទេសទាំងនោះត្រូវបានគេចំអិនភ្លាមនិងហូបបានភ្លាម។ ហើយវាមានបាក់តេរី Bacillus, Staphylococcus, Clostridium, Vibrio, Campylobacter, Listeria, Salmonella (Rane, ២០១១) ដោយសារវានៅហាលវាលប៉ះពាល់ជាមួយបរិយាកាសជុំវិញ បំពុលកើតចេញមកពីការធ្វើចរាចរណ៍ និងការមិនមានអនាម័យរបស់អាជីវករលក់ដូរតាមដងផ្លូវ។

**Table 1**

Source and type of hazard and the microbial risk involved

| S.No. | Source | Hazard | Risk involved |
|---|---|---|---|
| 1 | Vendor location | Improper food handling | Transfer of pathogens like *Salmonella* and *E. coli*, *S. aureus* from human body and environment into foods |
| | | Improper waste disposal | Transmission of enteric pathogens like *Salmonella*, *Shigella* and *E. coli* via vectors |
| 2 | Raw materials | Water | Passage of pathogens like *E. coli*, fecal streptococci, *Salmonella* and *Vibrio cholerae* |
| | | Vegetables and spices | Introduction sporeformers like Bacilli and Clostridium and pathogens like *L. monocytogenes*, *Shigella*, *Salmonella*, etc. |
| 3 | Utensils and equipments | Chemical contaminants | Leaching of chemical leading to poisoning |
| | | Microbial contaminants | Cross contamination of food with *Staphylococcus aureus*, *E. coli* and *Shigella* due to contaminated water, dish cloth, handler |
| 4 | Storage and reheating | Improper storage temperature and reheating of food | Likelihood of heat stable toxins produced by pathogens like *C. perfringens* and *B. cereus* |
| 5 | Personal hygiene of vendors | Biological hazards | Introduction of *Staphylococcus*, *Salmonella* and *Shigella* via carriers |

កំណត់សម្គាល់៖ ដកស្រង់ចេញមកពី *ចំណីអាហារដើរលក់តាមផ្លូវនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍៖ ការវិភាគពីគ្រោះថ្នាក់* ដោយ Sharmila Rane ២០១១. រក្សាសិទ្ធិ ២០១១ ដោយ Indian J Microbiol។

កង្វះកន្លែងលក់ដូរដ៏សមស្រប ក៏ជាកត្តាដ៏សំខាន់មួយដែលរួមចំណែកធ្វើមិនឱ្យមានសុវត្ថិភាពចំណីអាហាររបស់ស្ត្រីជាអ្នកលក់ដូរតាមដងផ្លូវនៅក្នុងប្រទេសកម្ពុជាផងដែរ។ មានឬគ្មានការប្រឹងប្រែងបន្តិចបន្តួចទាល់តែសោះ ក្នុងការផ្តល់ទីកន្លែងលក់ដូរដ៏សមរម្យដល់អាជីវករលក់ដូរតាមដងផ្លូវនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ មន្ត្រីសាធារណៈចាត់ទុកអាជីវករលក់ដូរតាមដងផ្លូវថាជាអ្នករំលោភចំណីផ្លូវសាធារណៈជាជាងមើលឃើញថាពួកគេជាជនក្រីក្រ ដែលព្យាយាមរកមួយថ្ងៃដើម្បីរស់មួយថ្ងៃ។ អ្នកនាំពាក្យសាលាក្រុងភ្នំពេញម្នាក់ត្រូវបានគេស្រង់សំដីថា "យើងបានជូនដំណឹងកាលពីខែមុនដល់ខណ្ឌទាំង១២ ឱ្យចាត់វិធានការដើម្បីរំដោះផ្លូវសាធារណៈពីអ្នកលក់តាមដងផ្លូវ និងអ្នកដែលកំពុងប្រើប្រាស់ដងផ្លូវធ្វើអាជីវកម្មឯកជន" (Koemsoeun, ២០១៧)។ សេចក្តីព្រាងច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈថ្មីៗនេះបញ្ជាក់ថាការអះអាងបែបនេះជាការពិត។ ខ្លឹមសារ និងបទប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់នេះត្រូវបានគេមើលឃើញថាជាច្បាប់ដាក់ការគាបសង្កត់មួយដល់អ្នកទាំងឡាយណាដែលនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជាពិសេសអាជីវករលក់ដូរតាមដងផ្លូវ (អង្គការឃ្លាំមើលសិទ្ធិមនុស្ស, ២០២០)។ លើសពីនេះ ប្រសិនបើច្បាប់នេះត្រូវចូលជាធរមាន សេចក្តីព្រាងច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈនេះ នឹងបង្កការគម្រាមកំហែងធ្ងន់ធ្ងរដល់សិទ្ធិសេដ្ឋកិច្ចសង្គម និងការប្រកបរបរចិញ្ចឹមជីវិតរបស់អាជីវករលក់ដូរតាមដងផ្លូវជាក់ជាមិនខាន។ គេជឿថាការផ្តល់ទីកន្លែងលក់ដូរដ៏សមរម្យ នឹងរួមចំណែកដល់ការពង្រឹងការប្រកបរបររកស៊ីចិញ្ចឹមជីវិតរបស់អាជីវករលក់ដូរតាមដងផ្លូវទាំងនោះ និងលើកកម្ពស់កាន់តែប្រសើរនូវសុវត្ថិភាពចំណីអាហារនៅក្នុងប្រទេសកម្ពុជា។

ការប្រឹងប្រែងលើកកម្ពស់ការយល់ដឹងជាសាធារណៈ ជាពិសេស អាជីវករលក់ដូរតាមដងផ្លូវ អាចរួមចំណែកដល់ការលើកកម្ពស់ឱ្យប្រសើរឡើងនូវសុខភាពសាធារណៈនៅក្នុងប្រទេសកម្ពុជា។ តួលេខពីការសិក្សាវាយតម្លៃបង្ហាញថាមានតែ ៤០.៩៨% នៃអ្នកឆ្លើយសំណួរប៉ុណ្ណោះដែលបញ្ជាក់ថា ពួកគេបានទទួលការបណ្តុះបណ្តាលអំពីសុវត្ថិភាពចំណីអាហារ។ ការសិក្សាផ្សេងទៀតកត់សម្គាល់ថា ការពិនិត្យមើល

សុវត្ថិភាពចំណីអាហារមិនបានល្អ ជាញឹកញាប់វាមានទំនាក់ទំនងជាមួយចំណីអាហារតាមផ្លូវ (Ma et al., ២០១៩)។ នេះឆ្លុះបញ្ចាំងឱ្យឃើញអំពីបញ្ហាប្រឈមឥតឈប់ឈររបស់កម្ពុជាក្នុងការលើកកម្ពស់ការធ្វើអនាម័យល្អ និងការយល់ដឹងអំពីសុវត្ថិភាពចំណីអាហារនៅក្នុងប្រទេស។ តាមពិតសូម្បីតែមានប្រជាពលរដ្ឋដែលទទួលបានការអប់រំល្អរបស់ប្រទេស ដូចជា និស្សិតវ័យក្មេង និងនិស្សិតសាកលវិទ្យាល័យ ក៏ចំណេះដឹងរបស់ពួកគេអំពីបញ្ហាអនាម័យនៅមានកម្រិតទាបនៅឡើយ (Cheng & Miriam, ២០១៦)។ ដោយសារភាគច្រើននៃអ្នកឆ្លើយសំណួរគឺជាអ្នកលក់អាហារចម្អិនស្រាប់ សាច់ និងផ្លែឈើ ការយល់ដឹង និងការប្រតិបត្តិសុវត្ថិភាពចំណីអាហារពិតជាមានសារៈសំខាន់ខ្លាំងណាស់។ ហើយទោះបីជាច្បាប់ស្តីពីសុវត្ថិភាពចំណីអាហារដែលរំពឹងថានឹងត្រូវបានអនុម័តក្នុងពេលឆាប់ៗនេះ (Pisei,២០២១) ស្ថាប័នរដ្ឋាភិបាលរួមទាំងសមាជិកនៃអង្គការ CSOs ក៏ត្រូវទទួលខុសត្រូវក្នុងការធានាថា អាជីវករលក់ដូរតាមដងផ្លូវទទួលបាននូវការបណ្តុះបណ្តាល និងការផ្សព្វផ្សាយជាសាធារណៈដ៏ចាំបាច់អំពីសុវត្ថិភាពចំណីអាហារ។




*រូបទី ៧ & ៨. ការបណ្តុះបណ្តាលអំពីសុវត្ថិភាពចំណីអាហារ និងការយល់ដឹង*

## ៧.៣. ភាពជាតំណាង និងការចរចាជាសមូហភាព

កង្វះភាពជាតំណាងរបស់ស្ត្រីជាអ្នកលក់ដូរតាមដងផ្លូវ បានកំហិតសមត្ថភាពរបស់ពួកគេក្នុងការប្រមូលសម្លេងតែមួយ និងអំណាចចរចារួម។ ខៈណៈកម្មកររោងចក្រកាត់ដេរមានអំណាចចរចារួមកាន់តែខ្លាំង ដែលទាក់ទាញអ្នកធ្វើគោលនយោបាយទាំងពីគណៈបក្សកាន់អំណាច និងគណៈបក្សប្រឆាំងអាជីវករលក់ដូរតាមដងផ្លូវជាញឹកញាប់ស្ថិតនៅក្រោយអ្នកទាំងនោះ។ តាមពិត សម្លេងរួមរបស់កម្មកររោងចក្រកាត់ដេរមានឥទ្ធិពលទៅលើឥស្សរៈជននយោបាយ ដែលធ្វើឱ្យពួកគេអាចទាមទារឱ្យមានការតម្លើងប្រាក់ឈ្នួលអប្បបរមារបស់ពួកគេ (Arnold, ២០១៣)។ ទោះដូច្នេះក៏ដោយ អាជីវករលក់ដូរតាមដងផ្លូវមិនមានតំណាងដោយសារតែកង្វះបណ្តាញសម្របសម្រួល និងផ្សព្វផ្សាយ។ ជាផលវិបាក ឥទ្ធិពលដ៏ខ្លាំងក្លារបស់ពួកគេទៅលើអ្នកនយោបាយ និងស្ថាប័នរដ្ឋាភិបាលមិនសូវមាន ដូច្នេះវាធ្វើឱ្យរដ្ឋាភិបាលមិនចាប់អារម្មណ៍ និងធ្វើអន្តរាគមន៍ផ្នែកគោលនយោបាយ។

ទិន្នន័យបែបគុណភាព បង្ហាញថាមាន ៦៦.៣៩% នៃអ្នកឆ្លើយសំណួរសរុបគឺជាសមាជិកនៃសមាគម IDEA ដែល ៣២.៣៨% នៃអ្នកផ្សេងទៀតមិនមានការពាក់ព័ន្ធជាមួយសមាគមសេដ្ឋកិច្ចក្រៅប្រព័ន្ធណាមួយនោះទេ។ ហើយមាន ៤២.៦២% នៃអ្នកឆ្លើយសំណួរសរុបចំនួន ៦៦.៣៩% ដែលជាសមាជិកនៃសមាគម IDEA បញ្ជាក់ថា ពួកគេមិនបានដឹងថា ផលប្រយោជន៍របស់ពួកគេត្រូវបានការពារដោយ IDEA និងថាពួកគេត្រូវបានសមាគមជួយពង្រឹងសិទ្ធិអំណាចរបស់ពួកគេឬមួយយ៉ាងណា។ ភស្តុតាងនៃសាច់រឿងនានាបញ្ជាក់ថាកង្វះការចងក្រងជាសហជីពនៃអាជីវករលក់ដូរតាមដងផ្លូវ អាចបណ្តាលមកពីកង្វះការផ្សព្វផ្សាយជាសាធារណៈ និងភាពជឿជាក់។ បើប្រៀបធៀបទៅវិស័យកាត់ដេរសម្លៀកបំពាក់ ការធ្វើសហជីពមានចំនួនជិត ៦០% (Nuon & Serrano, ២០១០, p. ១៨) ដែលសមាគម IDEA គឺជាសមាគមមានទំហំល្មមតែមួយគត់ដែលអាជីវករលក់ដូរតាមដងផ្លូវអាចពឹងពាក់បាន។ លើសពីនេះ កង្វះការផ្សព្វផ្សាយជាសាធារណៈ និងការលើកទឹកចិត្តបានបំបាក់ទឹកចិត្តស្ត្រីជាអ្នកលក់ដូរតាមដងផ្លូវបន្ថែមទៀត មិនឱ្យចូលរួមនៅក្នុងសហជីព ដែលនេះវាធ្វើឱ្យប៉ះពាល់ដល់សក្តានុពលរបស់ពួកគេសម្រាប់ធ្វើការចរចារួមដ៏រឹងមាំ។




*រូបភាពទី ៩& ១០. ការចូលជាសមាជិក និងកម្រិតនៃភាពជាតំណាង*

## ៧.៤. ការយល់ដឹងអំពីច្បាប់ និងគោលនយោបាយ

ទោះបីជាទិន្នន័យ បង្ហាញអំពីសមាមាត្រដ៏ធំនៃអ្នកឆ្លើយសំណួរជាក្រុមគោលដៅបានរៀនសូត្រត្រឹមត្រូវក៏ដោយ ក៏ការយល់ដឹងរបស់ពួកគេអំពីច្បាប់ការពារសិទ្ធិ និងការប្រកបរបររកស៊ីរបស់ពួកគេនៅមានកម្រិត។ តាមការប៉ាន់ប្រមាណថាមាន ៥២.៤៦% នៃអ្នកឆ្លើយសំណួរសរុបមិនបានដឹងអំពីច្បាប់បែបនោះឡើយ។ ដូចគ្នានេះដែរ មានប្រហែល ៥២.០៥% នៃអ្នកឆ្លើយសំណួរ មិនយល់អំពីខ្លឹមសារនៃរបបគាំពារសង្គម។ ទោះដូច្នេះក្តីសេចក្តីព្រាងច្បាប់ថ្មីៗនេះស្តីពីសណ្តាប់ធ្នាប់សាធារណៈបានទទួលការរិះគៀនជាសាធារណៈ (Aun & Baliga, ២០២០) ហើយវានឹងគម្រាមកំហែងដល់សិទ្ធិសេដ្ឋកិច្ចសង្គមរបស់ពួកគេ ការយល់ដឹង និងចំណេះដឹងរបស់ស្ត្រីជាអ្នកលក់ដូរតាមដងផ្លូវនៅតែជាកង្វល់។ នេះឆ្លុះបញ្ចាំងអំពីស្ថានការណ៍ទូទៅរបស់ប្រជាពលរដ្ឋកម្ពុជា នេះបើនិយាយអំពីការយល់ដឹងជាសាធារណៈ និងចំណេះដឹងអំពីច្បាប់ និងគោលនយោបាយពាក់ព័ន្ធជាមួយសិទ្ធិ និងភាពធន់របស់ពួកគេ។ ការយល់ដឹងរបស់ ពួកគេមានសារៈសំខាន់ណាស់ដើម្បីកសាងការចូលរួម និងអំណាចចរចារួមដ៏រឹងមាំមួយ។ វាក៏ត្រូវមានការសម្របសម្រួលជាយុទ្ធសាស្ត្រ និងយុទ្ធនាការផ្សព្វផ្សាយជាសាធារណៈពីស្ថាប័នរដ្ឋាភិបាល និងសមាជិកអង្គការ CSOs ដើម្បីធានាថា គេអាចរកបានដោយងាយស្រួលនូវច្បាប់ និងគោលនយោបាយដែលពាក់ព័ន្ធជាមួយក្រុមងាយរងគ្រោះដូចជាស្ត្រីជាអ្នកលក់ដូរតាមដងផ្លូវជាដើម។




*រូបទី ១១ & ១២. ការយល់ដឹងអំពីច្បាប់ការពារសិទ្ធិ និងការប្រកបរបររកស៊ីចិញ្ចឹមជីវិត និងរបបគាំពារសង្គម*

## ៧.៥. បញ្ហាកូវីដ-១៩ និងការគាំទ្រជំនួយសង្គ្រោះបន្ទាន់

បញ្ហាជម្ងឺកូវីដ-១៩ បានបង្កជាបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរដល់ការប្រកបរបររកស៊ីចិញ្ចឹមជីវិត និងសុខុមាលភាពរបស់ប្រជាពលរដ្ឋក្រីក្រខ្លាំងជាច្រើន នៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធជាពិសេសក្នុងចំណោមស្ត្រីជាអ្នកលក់ដូរតាមដងផ្លូវ។ ជាការពិតសេដ្ឋកិច្ចក្រៅប្រព័ន្ធបានរួមចំណែកយ៉ាងច្រើនដល់ការអភិវឌ្ឍ ការបង្កើតមុខរបរ និងការងារ សេវា និងឱកាសបង្កើតប្រាក់ចំណូល សម្រាប់ប្រជាពលរដ្ឋនៅទីប្រជុំជននៃប្រទេសកម្ពុជា (Heinonen, ២០០៨)។ និយាយម្យ៉ាងទៀត វិស័យនេះគឺជាខ្សែជីវិតមួយរបស់

អ្នកក្រីក្រខ្លាំងជាច្រើននាក់នៅទូទាំងប្រទេស។ វិស័យនេះក៏បានដើរតួនាទីដ៏សំខាន់របស់ខ្លួនក្នុងការទាក់ទាញភ្ញៀវទេសចរបរទេសមកកាន់ប្រទេសកម្ពុជាផងដែរ។ ក៏ប៉ុន្តែការរាតត្បាតជម្ងឺកូវីដ-១៩ បានធ្វើឱ្យវិស័យនេះជាប់គាំងដែលតម្រូវឱ្យមានការជួយគាំទ្រ និងជំនួយសង្គ្រោះបន្ទាន់ក្នុងទម្រង់ណាមួយក៏ដោយដើម្បីឱ្យវិស័យនេះដំណើរការបានជានិរន្តរ៍។

**Table 3**
Rents and Taxes vendors pay in different markets in Phnom Penh.

| | Rent/taxes | Electricity/water | "P'sy" price and cleansing price |
|---|---|---|---|
| Doeum Kor Market | | | |
| Vegetable | No information | | |
| Fruits | 150,000r ($37.5) or up to 300,000r ($75) per month rent | | |
| Cooking spices | $300 per month rent | 5000r per cubic meter | |
| Orussey Market | | | |
| Cooking spices | | 1500 khr per kilowatt for the use of electricity | 300khr and 200khr "P'sy" price and cleansing price respectively every day and 20,000khr for market security services monthly. |
| Curtains | | 1500 khr per kilowatt for the use of electricity | 200khr and 100khr daily for the "P'sy" price and cleansing price to the market respectively and pay 20,000 khr monthly for security services. |
| Hair accessories | $700 per month for the rental fee. | 1500 khr per kilowatt for the use of electricity | 200 khr daily for the "P'sy" price and 100khr for the cleaning fee and pay 20,000 khr monthly for security services |
| Russian Market | | | |
| Souvenir | Renting fee $300 to $600 monthly but the majority pays $350 as the stall fee. Pay 57,000 riels annually to the state | Average electricity fee ranges between 40,000 riels to 60,000 riels | |
| Clothing: clothing from Thailand and clothing from factory | Renting fee range from $350 to $700 monthly, 15,000 riels to the officers in the market | Average electricity fee ranges between 40,000 riels to 60,000 riels | |
| Motorcycle machine parts: seat, wheel and disc brake | 15,000 riels to the officer in the markets | Average electricity fee ranges between 40,000 riels to 60,000 riels | |

កំណត់សម្គាល់៖ ដកស្រង់ចេញមកពី *ការលក់ដូរតាមដងផ្លូវនៅផ្សារទីប្រជុំជន "ក្រៅប្រព័ន្ធ"៖ ការឆ្លុះបញ្ចាំងពីករណីសិក្សានៃអាជីវករលក់ដូរតាមដងផ្លូវនៅទីក្រុងដេលី (ប្រទេសឥណ្ឌា) និងក្រុងភ្នំពេញ (ប្រទេសកម្ពុជា)* ដោយ Sekhani et al., ២០១៩. រក្សាសិទ្ធិ ២០១៩ ដោយ ScienceDirect។

បញ្ហាប្រឈមបន្ទាន់សម្រាប់ស្ត្រីជាអ្នកលក់ដូរតាមដងផ្លូវគឺការបង់ភាស៊ី និងកម្រៃផ្សេងៗ។ អ្នកឆ្លើយសំណួរជាក្រុមគោលដៅទាំងនោះ បានគូសបញ្ជាក់អំពីបញ្ហាប្រឈមមួយចំនួនដែលពួកគេកំពុងជួបប្រទះក្នុងអំឡុងកូវីដ-១៩។ បញ្ហាប្រឈមចម្បងក្រៅពីបញ្ហាបច្ចុប្បន្នរបស់ពួកគេគឺចំនួនភាគរយទាបបំផុតនៃអតិថិជន ដែលពួកគេមិនធ្លាប់ជួបប្រទះពីមុន។ នេះប្រហែលជាបណ្ដាលមកពីការផ្លាស់ប្ដូរទំនោរ និងការឆ្លើយតបរបស់អតិថិជនចំពោះការរាតត្បាតនៃជម្ងឺកូវីដ-១៩ ដែលអតិថិជនជាច្រើននាក់ងាកមកទិញទំនិញតាមអនឡាញ និងចំអិនអាហារនៅផ្ទះដើម្បីកាត់បន្ថយការឆ្លងជម្ងឺ។ ភាគរយតិចបំផុតនៃអតិថិជនមានន័យថាខ្វះ ឱកាសបង្កើតប្រាក់ចំណូលសម្រាប់ចំណាយផ្សេងៗ ដូចជាថ្លៃជួលកន្លែងលក់ដូរជាដើម។ ការសិក្សាផ្សេងទៀតកត់សម្គាល់ថា អ្នកលក់ដូរម្នាក់នៅក្នុងទីក្រុងភ្នំពេញបង់ប្រាក់ប្រហែល $៣៧.៥ ឬ $៧៥ ក្នុង ១ខែតែទៅលើពន្ធ/ភាស៊ី និងថ្លៃជួលកន្លែងលក់ដូរតែមួយមុខប៉ុណ្ណោះ (Sekhani et al., ២០១៩, p. ១២៤)។ ដោយសារសមាមាត្រដ៏ច្រើននៃពួកគេ បានធ្វើចំណាកស្រុកពីតំបន់ជនបទ ពួកគេចាំបាច់ក៏ត្រូវការបង់ថ្លៃជួលកន្លែងស្នាក់នៅផងដែរ។ ទាំងនេះវាបង្កជាការគម្រាមកំហែងដ៏ធ្ងន់ធ្ងរទៅលើឯករាជ្យភាពហិរញ្ញវត្ថុ សុខុមាលភាពសេដ្ឋកិច្ច និងសុខភាពផ្លូវចិត្តរបស់ស្ត្រីជាអ្នកលក់ដូរតាមដងផ្លូវទាំងនោះ ដែលអាចបណ្ដាលឱ្យមានជាវិបត្តិសុខភាពសាធារណៈរយៈពេលវែងមួយ។




*រូបទី ១៣. តើជំនួយគាំទ្រទាំងនោះបានជួយដោះស្រាយបញ្ហាប្រឈមរបស់អ្នកបានទំហំប៉ុណ្ណា?*

## ៧.៦. ការឆ្លើយតបរបស់រដ្ឋាភិបាលក្នុងឆ្នាំ ២០២០

ការសិក្សាវាយតម្លៃក្នុងឆ្នាំ ២០២០ ដែលធ្វើឡើងដោយ API បង្ហាញអំពីសំណូមពរធំៗចំនួន ៣ ពីអាជីវករលក់ដូរតាមដងផ្លូវ៖ ១) ស្នើសុំកន្លែងមើលថែទាំកុមារ ២) លើកលែងការយកពន្ធ/ភាស៊ី និងកម្រៃនានា និង ៣) ស្នើសុំទទួលបានបណ្ណពណ៌លឿង ឬបណ្ណ ប.ស.ស។ ជាអកុសលរហូតមកដល់ពេលនេះ សំណូមពរទាំង ៣នេះមិនត្រូវបានដោះស្រាយដោយរដ្ឋាភិបាល។ មានជាង ៩៧.៩៥% នៃអ្នកឆ្លើយសំណួរសរុបឆ្លើយថា អាជ្ញាធរមិនបានផ្តល់កន្លែង ថែទាំកុមារដល់ស្ត្រីជាអ្នកលក់ដូរតាមដងផ្លូវ។ តួលេខនេះនៅតែខ្ពស់ចំពោះការធ្វើអន្តរាគមន៍ ការយកពន្ធ/ភាស៊ី និងកម្រៃនានា។ មាន ៨០.៣៣% នៃអ្នកឆ្លើយសំណួរសរុបបានឆ្លើយថារដ្ឋាភិបាល ឬអាជ្ញាធរ មិនបានលើកលែងការយកថ្លៃជួលកន្លែងលក់ដូររបស់អាជីវករលក់ដូរតាមដងផ្លូវនោះឡើយ។ ហើយមានតែ ២៥% នៃពួកគេមានបណ្ណពណ៌លឿង ឬបណ្ណ ប.ស.ស។ ទាំងនេះបង្ហាញពីកង្វះការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហាប្រឈមដ៏ចម្បងរបស់អាជីវករលក់ដូរតាមដងផ្លូវនៅទូទាំងប្រទេសដែលគេគួរតែពិនិត្យឡើងវិញ។ តាមពិត ប្រជាពលរដ្ឋកម្ពុជា បានចំណាយប្រាក់ក្រៅហោប៉ៅរបស់ពួកគេលើការថែទាំសុខភាពដែលស្មើ ២/៣ នៃការចំណាយសម្រាប់គ្រួសារសរុប (Annear et al., ២០១៣, p.២២៥)។ វាមានសារៈសំខាន់ខ្លាំងណាស់ថារដ្ឋាភិបាលត្រូវធ្វើការពិចារណាអំពីការជួយគាំទ្រដ៏សំខាន់ទាំងនេះដល់(ស្ត្រី)អាជីវករលក់ដូរតាមដងផ្លូវទាំងនោះដើម្បីពង្រឹងភាពធន់ និងសុខុមាលភាពផ្នែកសេដ្ឋកិច្ចរបស់ពួកគេ។




*រូបទី ១៤, ១៥ & ១៦. ការធ្វើអន្តរាគមន៍របស់រដ្ឋាភិបាលក្នុងការដោះស្រាយសំណូមពរសំខាន់ៗក្នុងឆ្នាំ២០២០*







# ៨ សំណូមពរ និងតម្រូវការក្នុងឆ្នាំ២០២១

សំណូមពរ និងតម្រូវការសំខាន់ៗក្នុងឆ្នាំ២០២១ របស់ស្ត្រីជាអ្នកលក់ដូរតាមដងផ្លូវទាំងនោះ ស្រដៀងគ្នាទៅនឹងលទ្ធផលដែលទទួលបានពីការធ្វើអង្កេតតាមអនឡាញក្នុងឆ្នាំ ២០២០។ សំណើសុំឱ្យទទួលបានបណ្ណពណ៌លឿង (បណ្ណសមធម៌) ឬអត្ថប្រយោជន៍ ប.ស.ស នៅស្ថិតនៅលើតុនៅឡើយដែលមានអ្នកស្នើសុំចំនួន ៨៥.២៥% នៃអ្នកឆ្លើយសំណួរសរុប។ ដូចគ្នានេះផងដែរ សំណើសុំកម្ចីដោយមិនមានការប្រាក់




*រូបទី ១៧, សំណូមពរ និងតម្រូវការក្នុងឆ្នាំ ២០២១*

និងកម្ចីផ្សេងទៀតសម្រាប់ការវិនិយោគខ្នាតតូចមានចំនួន ៧៦.២៣% នៃអ្នកឆ្លើយសំណួរសរុប។ តាមការប៉ាន់ប្រមាណការវិនិយោគខ្នាតតូចនៅទីនេះមានតម្លៃរវាងពី $US៥០០ ទៅ $US៣,០០០ដោយផ្អែកលើការសាកសួរតាមអនឡាញដែលបានធ្វើចាប់ពីថ្ងៃទី ១៣ ដល់ថ្ងៃទី ១៩ ខែឧសភាឆ្នាំ ២០២១ នៅក្នុងទីក្រុងបាត់ដំបង ក្រុងភ្នំពេញ និងក្រុងសៀមរាប។ សំណើដ៏គួរឱ្យចាប់អារម្មណ៍មួយទៀតគឺសំណើសុំឱ្យមានការបណ្តុះបណ្តាលអំពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលមានអ្នកឆ្លើយចំនួន ៤៩.៥៩% នៃអ្នកឆ្លើយសំណួរសរុប។ ទាំងនេះវាតម្រូវឱ្យមានការតស៊ូមតិដែលមានការសម្របសម្រួលដ៏ល្អមួយសម្រាប់ការធ្វើអន្តរាគមន៍ផ្អែកគោលនយោបាយពីស្ថាប័នរដ្ឋាភិបាល។







*រូបទី ១៨ ១៩, សំណូមពរ និងតម្រូវការក្នុងឆ្នាំ ២០២១*

## ៩ តម្រូវការបណ្តុះបណ្តាល និងជំនាញ



ការបណ្តុះបណ្តាលជំនាញ និងការកសាងសមត្ថភាពវាមានសារៈសំខាន់ណាស់សម្រាប់ (ស្ត្រី) អាជីវករលក់ដូរតាមដងផ្លូវក្នុងការដោះស្រាយជាមួយការផ្លាស់ប្តូរនានាផ្នែកសេដ្ឋកិច្ចសង្គម។ ប្រធានបទនៃការបណ្តុះបណ្តាលខ្លះត្រូវបានជ្រើសរើសដោយអ្នកឆ្លើយសំណួរជាក្រុមគោលដៅ ហើយដែលឆ្លុះបញ្ចាំងយ៉ាងខ្លាំងអំពីចំណាប់អារម្មណ៍របស់ពួកគេ។ សំណើសុំការបណ្តុះបណ្តាលអំពីជំនាញទំនាក់ទំនងសាធារណៈជាមួយរដ្ឋាភិបាល និងជាមួយភាគីពាក់ព័ន្ធផ្សេងទៀតមានចំនួន ៧២.៥៤% នៃអ្នកឆ្លើយសំណួរសរុប។ ស្រដៀងគ្នានេះ សំណើសុំការបណ្តុះបណ្តាលអំពីច្បាប់ការពារសិទ្ធិក្នុងការធ្វើការងារ និងប្រកបរបររកស៊ីចិញ្ចឹមជីវិតសមរម្យមានចំនួន ៦៨.០៣% និង ៥២.៨៩% ស្នើសុំឱ្យមានការបណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ ហើយ ៥១.៦៥% ស្នើសុំការបណ្តុះបណ្តាលអំពីសិទ្ធិទទួលបានព័ត៌មាន។ ជំនាញ និងការកសាងសមត្ថភាពទាំងនេះមានសារៈសំខាន់ខ្លាំងណាស់ក្នុងការចងក្រងជាសហជីពដ៏ខ្លាំងក្លា និងការប្រមូលផ្តុំសម្លេងរួមរបស់ (ស្ត្រី) អាជីវករលក់ដូរតាមដងផ្លូវនៅទូទាំងប្រទេសកម្ពុជា។ ការកសាងសមត្ថភាពនឹងផ្តល់ជំនាញ និងចំណេះដឹងដល់ពួកគេដើម្បីបង្កើនការចងក្រងជាសហជីពរបស់ពួកគេ ដែលអាចឱ្យពួកគេមានឥទ្ធិពលទៅលើលទ្ធផលនៃគោលនយោបាយ និងសម្រេចបានផលប្រយោជន៍ជាយុទ្ធសាស្ត្ររបស់ពួកគេ។




*រូបទី ២០. ការបណ្តុះបណ្តាលសំខាន់ៗដែលបានស្នើឡើងក្នុងឆ្នាំ ២០២១*

## ១០ អនុសាសន៍

អនុសាសន៍ខាងក្រោមត្រូវបានបង្កើតឡើងដោយផ្អែកលើទិន្នន័យបែបគុណភាពនៃការសិក្សាវាយតម្លៃនេះ។

**អនុសាសន៍ចម្បងទី ១៖** ក្រុងភ្នំពេញ និងអាជ្ញាធរខេត្តគួរពិចារណាផ្តល់ទីកន្លែងលក់ដូរដ៏សមស្របសម្រាប់អាជីវករលក់ដូរតាមដងផ្លូវនៅតំបន់ជាយក្រុង។ ការអនុវត្តល្អៗពីប្រទេសជិតខាងគួរត្រូវបានយកមកពិចារណាដោយសារតែវាមានចរិកលក្ខណៈដូចគ្នាជាមួយបញ្ហាប្រឈមទាំងឡាយនៅក្នុងប្រទេសកម្ពុជា។ គម្រោងសាកល្បងយកផ្លូវ ឬទីកន្លែងមួយធ្វើជាកន្លែងលក់ដូរគឺជាការអនុវត្តល្អមួយ។ វាផ្តល់ដល់អាជ្ញាធរនូវឱកាសដើម្បីធ្វើការវាយតម្លៃផលប៉ះពាល់ និងកាត់បន្ថយហានិភ័យធំៗដែលបង្កដោយគំនិតផ្តួចផ្តើមនេះ មុនការអនុវត្ត និងការបន្សីគោលនយោបាយក្នុងទ្រង់ទ្រាយធំ។ ទាំងនេះវានឹងជួយដោះស្រាយបញ្ហាកេងប្រវ័ញ្ចដែលមានលក្ខណៈជាប្រព័ន្ធមកលើអាជីវករលក់ដូរតាមដងផ្លូវ និងការរំលោភយកដីចំណីផ្លូវ។

**អនុសាសន៍ចម្បងទី ២៖** គេគួរកំណត់ជាអាទិភាព និងផ្តល់ការបណ្តុះបណ្តាលអំពីសុវត្ថិភាពចំណីអាហារ និងការលក់ចំណីអាហារតាមដងផ្លូវដល់អាជីវករលក់ដូរតាមដងផ្លូវដើម្បីលើកកម្ពស់ឱ្យកាន់តែប្រសើរនូវសុវត្ថិភាពចំណីអាហារ និងសុខភាពសាធារណៈនៅក្នុងប្រទេសកម្ពុជា។ ក្រៅពីនេះ វាសំខាន់ណាស់ត្រូវធានាថាអាជីវករលក់ដូរតាមដងផ្លូវទទួលបាននូវប្រព័ន្ធប្រមូលសម្រាមប្រកបដោយប្រសិទ្ធិភាព ទឹកស្អាតប្រើប្រាស់ និងកន្លែងទុកដាក់សម្រាម។ គួរគិតគូរពិចារណាឱ្យមានគោលនយោបាយលើកទឹកចិត្ត និងគោលនយោបាយច្បាប់ដើម្បីលើកទឹកចិត្តឱ្យមានការចូលរួម។ ទាំងនេះវានឹងរួមចំណែកដល់ការលើកកម្ពស់ឱ្យកាន់តែប្រសើរនូវចំណេះដឹងអំពីសុវត្ថិភាពចំណីអាហារ និងឥរិយាបថរបស់អាជីវករលក់ដូរតាមដងផ្លូវនៅក្នុងប្រទេសកម្ពុជា។ ជាលទ្ធផល វានឹងពង្រឹងសុខភាពសាធារណៈ និងជម្រុញការទាក់ទាញភ្ញៀវទេសចរមកក្នុងប្រទេស។

**អនុសាសន៍ចម្បងទី ៣៖** IDEA និងតួអង្គផ្សេងទៀតគួរពិចារណាធ្វើការផ្សព្វផ្សាយជាសាធារណៈឱ្យកាន់តែខ្លាំងក្លា និងការលើកទឹកចិត្តដើម្បីបង្កើនសមាជិកភាព និងការចងក្រងសហជីពក្នុងចំណោម (ស្ត្រី) អាជីវករលក់ដូរតាមដងផ្លូវ។ នេះវានឹងកសាងបាននូវភាពជាតំណាងមួយ និងការចរចារួមកាន់តែខ្លាំង ដែលអាចឱ្យពួកគេមានសមត្ថភាពក្នុងការចរចា និងមានឥទ្ធិពលទៅលើថ្នាក់ដឹកនាំនយោបាយដើម្បីសម្រេចបាននូវផលប្រយោជន៍របស់ពួកគេ។

ដោយសារធនធាន និងបុគ្គលិករបស់ IDEA មានកម្រិត ការផ្សព្វផ្សាយជាសាធារណៈ និងការលើកទឹកចិត្តបែបនោះ គួរផ្តល់អត្ថប្រយោជន៍ និងផ្តោតលើ(ស្ត្រី)អាជីវករលក់ដូរតាមដងផ្លូវនៅតំបន់ទីប្រជុំជនដែលពួកគេកំពុងជួបបញ្ហាប្រឈមធ្ងន់ធ្ងរជាង បើប្រៀបធៀបទៅអាជីវករលក់ដូរតាមដងផ្លូវផ្សេងទៀតនៅស្រុកស្រែចំការ។




**អនុសាសន៍ចម្បងទី ៤៖** រាជរដ្ឋាភិបាលកម្ពុជា គួរពិចារណាផ្តល់នូវកិច្ចការពារផ្លូវច្បាប់ដល់អាជីវករលក់ដូរតាមដងផ្លូវពីការរំលោភបំពាន និងការកេងប្រវ័ញ្ចជាលក្ខណៈប្រព័ន្ធ។ ហើយដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា ជាពិសេស គោលដៅទី ៨ (ការងារសមរម្យ & កំណើនសេដ្ឋកិច្ច) និងគោលដៅទី ១០ (កាត់បន្ថយវិសមភាព) វាចាំបាច់ថាអាជីវករលក់ដូរតាមដងផ្លូវទាំងនោះត្រូវបានគាំពារទាំងគោលនយោបាយ និងច្បាប់ការពារមួយដែលមានប្រយោជន៍ដល់ការពង្រឹងភាពធន់របស់ពួកគេ។

**អនុសាសន៍ចម្បងទី ៥៖** ក្រសួងមហាផ្ទៃ គួរពិនិត្យមើលឡើងវិញនូវសេចក្តីព្រាងច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈនេះដើម្បីធានាថាច្បាប់នេះការពារផលប្រយោជន៍ និងពង្រឹងអំណាចរបស់ប្រជាពលងាយរងគ្រោះបំផុត។ មានការស្នើសុំថាគួរមានការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ និងការផ្សព្វផ្សាយជាសាធារណៈដើម្បីកសាងជំនឿសាធារណៈជន ការគោរពគ្នាទៅវិញទៅមក និងធានានូវការចូលរួមដ៏សកម្មពី(ស្ត្រី)អាជីវករលក់ដូរតាមដងផ្លូវ។

**អនុសាសន៍ចម្បងទី ៦៖** រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសប្បុរសធម៌គួរពិចារណាពិនិត្យឡើងវិញនូវកម្មវិធីជំនួយសង្គ្រោះបន្ទាន់ចំពោះបញ្ហាកូវីដ-១៩នេះ។ គេគួររៀបចំកម្មវិធីមួយដែលធ្វើឱ្យមានផលប៉ះពាល់ជាវិជ្ជមានរយៈពេលវែង ជាជាងគ្រាន់តែផ្តល់ស្បៀង និងគ្រឿងទេស។ ដោយផ្អែកលើទិន្នន័យបែបគុណភាព ជំនួយសង្គ្រោះបន្ទាន់ដែលចាំបាច់សម្រាប់អាជីវករលក់ដូរតាមដងផ្លូវ គឺការលើកលែងការបង់ពន្ធ/ភាស៊ី និងកម្រៃការពារនានា រួមទាំងការឧបត្ថម្ភធន ដ៏ច្រើនសម្រាប់គាំទ្រការបង់ថ្លៃជួលកន្លែងស្នាក់នៅរបស់ពួកគេ។

**អនុសាសន៍ចម្បងទី ៧៖** មានការស្នើថារាជរដ្ឋាភិបាលកម្ពុជាគួរពិនិត្យឡើងវិញ និងធ្វើការដោះស្រាយនូវសំណើធំៗទាំង ៣របស់អាជីវករលក់ដូរតាមដងផ្លូវដែលបានលើកឡើងតាំងពីឆ្នាំ ២០២០ គឺ ១) កន្លែងថែទាំកុមារ ២) ការលើកលែងការយកពន្ធ/ភាស៊ីលក់ដូរ និង ៣) ការទទួលបានបណ្ណពណ៌លឿង ឬអត្ថប្រយោជន៍ ប.ស.ស។ ធ្វើបែបនេះវានឹងរួមចំណែកដល់ការលើកកម្ពស់សុខុមាលភាពផ្នែកសេដ្ឋកិច្ចរបស់ពួកគេ និងបង្ហាញពីការប្ដេជ្ញាចិត្តដ៏រឹងមាំរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះសុខភាពល្អ និងសុខុមាលភាពសមភាពយេនឌ័រ និងការកាត់បន្ថយវិសមភាពដែលមានចែងជាបញ្ហាអាទិភាព នៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា។

**អនុសាសន៍ចម្បងទី ៨៖** សមាជិកអង្គការ CSOs និងសហជីពគួរពិចារណាការវិភាជន៍ និងផ្ដល់ប្រាក់កម្ចីគ្មានការប្រាក់ និងកម្ចីមានការប្រាក់ទាបដល់(ស្ត្រី)អាជីវករលក់ដូរតាមដងផ្លូវសម្រាប់ធ្វើវិនិយោគខ្នាតតូច។ ការមិនទទួលបានហិរញ្ញវត្ថុ ពិតជាបញ្ហាប្រឈមធំមួយសម្រាប់ (ស្ត្រី)អាជីវករលក់ដូរតាមដងផ្លូវក្នុងការដាក់ទុនវិនិយោគខ្នាតតូច ដូច្នេះវាធ្វើឱ្យប៉ះពាល់ដល់សក្ដានុពលនៃវិស័យនេះ។ គេគួររៀបចំគំនិតផ្ដួចផ្ដើមនេះដើម្បីជម្រុញឱកាសមុខរបរ និងការងារ និងគំនិតច្នៃប្រឌិតចំពោះទំនិញ និងការផ្ដល់សេវា។ ទាំងនេះវានឹងគាំទ្រដល់ស្ត្រីជាអ្នកលក់ដូរតាមដងផ្លូវទាំងនោះឱ្យអាចដោះស្រាយបាននូវបញ្ហានានាដែលបង្កឡើងដោយការរាតត្បាតនៃជម្ងឺកូវីដ-១៩។



# ១១ ឯកសារយោង


Annear, P. L., Ahmed, S., Ros, C. E., & Ir, P. (2013). Strengthening institutional and organizational capacity for social health protection of the informal sector in lesser-developed countries: A study of policy barriers and opportunities in Cambodia. *Social Science & Medicine*, 96, 223–231. https://doi.org/10.1016/j.socscimed.2013.02.015

Arnold, D. (2013). Workers' Agency and Re-Working Power Relations in Cambodia's Garment Industry. *SSRN Electronic Journal*. https://doi.org/10.2139/ssrn.2237494

ASEAN. (2019). *Regional Study on Informal Employment Statistics to Support Decent Work Promotion in ASEAN.* https://asean.org/storage/2012/05/13-Regional-Study-on-Informal-Employment-Statistics-to-Support-Decent-Wo....pdf

Asia Foundation. (2011). *Cambodia's Labor Migration: Analysis of the Legal Framework*. 78.

Aun, C., & Baliga, A. (2020). Draft Public Order Law Looks to Control Cambodians' Behavior and Activities. *VOA*. https://www.voacambodia.com/a/draft-public-order-law-looks-to-control-cambodians-behavior-and-activities/5502253.html

Cheng, M., & Miriam, S. (2016). *How (un)healthy and (un)safe is food in Cambodia?* Konrad-Adenauer-Foundation Cambodia. https://www.kas.de/c/document_library/get_file?uuid=49714e0a-071d-3e3a-ffb4-f2351af7da40&groupId=252038#:~:text=By%20Cambodian%20law%2C%20food%20products,be%20eliminated%20from%20the%20market.

Heinonen, U. (2008). *The Hidden Role of Informal Economy: Is Informal Economy Insignificant for Phnom Penh's Development?*

Human Rights Watch. (2020, August 13). *Civil Society Organizations Call for the Draft Law on Public Order to be Immediately Discarded*. https://www.hrw.org/news/2020/08/13/civil-society-organizations-call-draft-law-public-order-be-immediately-discarded

*IDEA*. (2021). http://www.ideacambodia.org/pages/index.php?p=publish

International Labor Organisation. (2015). *Review of the effectiveness of the MOUs in managing labour migration between Thailand and neighbouring countries*. ILO. http://www.ilo.org/public/libdoc/ilo/2015/487359.pdf

Koemsoeun, S. (2017). *Street vendors kicked off the kerb in Phnom Penh*. https://www.phnompenhpost.com/national/street-vendors-kicked-kerb-phnom-penh

Lawreniuk, S., & Parsons, L. (2017). After the exodus: Exploring migrant attitudes to documentation, brokerage and employment following the 2014 mass withdrawal of Cambodian workers from Thailand. *Singapore Journal of Tropical Geography*, 38(3), 350–369.

Ma, L., Chen, H., Yan, H., Wu, L., & Zhang, W. (2019). Food safety knowledge, attitudes, and behavior of street food vendors and consumers in Handan, a third tier city in China. *BMC Public Health*, 19(1), 1128. https://doi.org/10.1186/s12889-019-7475-9

Meta, K. (2017). *Health staffers said to have demanded cash*. https://www.phnompenhpost.com/national/health-staffers-said-have-demanded-cash

Meta, K. (2019). PM approves 2019 budget | *Phnom Penh Post*. https://www.phnompenhpost.com/national/pm-approves-2019-budget

National Institute of Statistics. (2019). *General Population Census of the Kingdom of Cambodia 2019* (pp. 1–21). Ministry of Planning. http://www.nis.gov.kh/nis/Census2019/Provisional%20Population%20Census%202019_English_FINAL.pdf

Nuon, V., & Serrano, M. (2010). *Building unions in Cambodia*.

Oxfam Cambodia. (2019). *Street Vendor Groups: Social Protection For The Informal Workers*. https://cambodia.oxfam.org/latest/policy-paper/street-vendor-groups#:~:text=In%20Cambodia%2C%20there%20are%20about,Penh%20and%2075%25%20are%20women.

Parsons, L. (2016). Mobile inequality: Remittances and social network centrality in Cambodian migrant livelihoods. *Migration Studies*, 4(2), 154–181. https://doi.org/10.1093/migration/mnw005

Pisei, H. (2019). *FDI to Cambodia rockets 12% to $3.5 billion in 2019*. https://www.phnompenhpost.com/business/fdi-cambodia-rockets-12-35-billion-2019

Pisei, H. (2021). *Food Safety Law to be enacted in 2021: Commerce official*. https://www.phnompenhpost.com/business/food-safety-law-be-enacted-2021-commerce-official

Rane, S. (2011). Street Vended Food in Developing World: Hazard Analyses. *Indian Journal of Microbiology*, 51(1), 100–106. https://doi.org/10.1007/s12088-011-0154-x

Sekhani, R., Mohan, D., & Medipally, S. (2019). Street vending in urban ‘informal’ markets: Reflections from case-studies of street vendors in Delhi (India) and Phnom Penh City (Cambodia). *Cities*, 89, 120–129. https://doi.org/10.1016/j.cities.2019.01.010

UNDP. (2016). *Overview of Internal Migration in Cambodia* (pp. 1–9) [Policy Brief]. https://bangkok.unesco.org/sites/default/files/assets/article/Social%20and%20Human%20Sciences/publications/Policy-brief-internal-migration-cambodia.pdf

Voun, D. (2021). *'No taxes' on market vendors in Preah Sihanouk* | Phnom Penh Post.
https://www.phnompenhpost.com/national/no-taxes-market-vendors-preah-sihanouk

World Bank. (2019). *Cambodia Overview*.
https://www.worldbank.org/en/country/cambodia/overview

World Food Programme. (2019). *Vulnerability and Migration in Cambodia*. World Food Programme.
https://docs.wfp.org/api/documents/WFP-0000105976/download/

# ១២ ឧបសម្ព័ន្ធ

## បញ្ជីនៃច្បាប់ និងគោលនយោបាយដែលបានពិគ្រោះយោបល់៖

- រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣ (ប្រទេសកម្ពុជា)
- គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ ២០១៥ (ប្រទេសកម្ពុជា)
- សេចក្តីព្រាងច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈឆ្នាំ ២០២០ (ប្រទេសកម្ពុជា)
- បេឡាជាតិសន្តិសុខសង្គមឆ្នាំ ២០១៨ (ប្រទេសកម្ពុជា)
- សហគ្រាសមីក្រូ ធុនតូច និងមធ្យមឆ្នាំ ២០១៩ (ប្រទេសកម្ពុជា)
- ក្របខណ្ឌគោលនយោបាយគាំពារសង្គមឆ្នាំ ២០១៦-២០២៥ (ប្រទេសកម្ពុជា)
- ផែនការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យមឆ្នាំ ២០២០-២០២៤ (ប្រទេសកម្ពុជា)
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០២០-២០៣០(ប្រទេសកម្ពុជា)

## បញ្ជីនៃរបាយការណ៍ដែលបានពិគ្រោះយោបល់៖

- API. (២០២០). Online Survey on Young Women Micro-entrepreneurs and Youth, Street Vendors in Phnom Penh
- ActionAid. (២០២០). Assessment of Economic Impacts of COVID-១៩ on Workers in Informal Sector of Cambodia
- Charadine and Hor. (២០២០). The Impact of COVID-១៩ PANDEMICS: NATIONAL & REGIONAL IMPLICATIONS
- Asia Foundation. (២០២០). Enduring the Pandemic: Rapid Survey on the Impact of Covid-១៩ on MSMEs in the Tourism Sector and Households in Cambodia

BUILDING CAPACITY FOR CHANGE

វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ
ADVOCACY AND POLICY INSTITUTE

# វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ

## អង្គការមិនមែនរដ្ឋាភិបាលឈានមុខមួយ ដែលសកម្មនៅក្នុងការតស៊ូមតិ ការជះឥទ្ធិពលលើគោលនយោបាយ ការកសាងសមត្ថភាព អភិបាលកិច្ចល្អ និងការសម្របសម្រួលកិច្ចសន្ទនារវាងប្រជាពលរដ្ឋ និងតួអង្គរបស់រដ្ឋ

វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) ជាអង្គការក្រៅរដ្ឋាភិបាលមួយរបស់កម្ពុជា ដែលសកម្មក្នុងការតស៊ូមតិការជះឥទ្ធិពលនយោបាយអភិបាលកិច្ចល្អនិងការចូលរួមរបស់ពលរដ្ឋ។ការកសាងសមត្ថភាព និងការសម្របសម្រួលកិច្ចសន្ទនាគឺជាចំណុចសំខាន់នៃកិច្ចខិតខំប្រឹងប្រែងរបស់យើងឆ្ពោះទៅរកការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

យើងទទួលបានការសារទរយ៉ាងទូលំទូលាយ ពីអង្គការក្នុងស្រុក និងអន្តរជាតិសម្រាប់ ភាពដែលអាចជឿជាក់បាន ភាពពាក់ព័ន្ធ និងវិជ្ជាជីវៈរបស់យើង។ ក្នុងរយៈពេលជិតពីរទសវត្សរ៍មកនេះ API បានជួយពង្រឹងជំនាញស្ថាប័នតស៊ូមតិនិងបានខិតខំធ្វើឲ្យលទ្ធិប្រជាធិបតេយ្យមូលដ្ឋាននិងអភិបាលកិច្ចដែលមានគណនេយ្យភាព ក្លាយទៅជាការពិត។ មកទល់នឹងពេលនេះ យើងបានបើក**<u>វគ្គបណ្តុះបណ្តាល</u>**ជាង ៣០០ មកហើយ សម្រាប់អ្នកចូលរួមជាង ១ ម៉ឺននាក់ ដែលមានទំនាក់ទំនងជាមួយសង្គមស៊ីវិល និងអង្គការសហគមន៍ ក្រុមប្រឹក្សា មូលដ្ឋាន ប្រព័ន្ធផ្សព្វផ្សាយ អង្គភាពសហជីព ស្ថាប័នរដ្ឋាភិបាល និងសភាកម្ពុជាផងដែរ។

API មានភាពប្លែកពីគេ នៅក្នុងសង្គមស៊ីវិលរបស់ប្រទេសកម្ពុជា ដោយបម្រើជាអ្នកភ្ជាប់ និងសម្របសម្រួលសម្រាប់ការផ្តល់សិទ្ធិអំណាចដល់ប្រជាជន ក្នុងការធ្វើអន្តរកម្មជាមួយរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់។ API ទទួលបានបទពិសោធន៍ដំបូងលើបញ្ហាគោលនយោបាយដូចជាការទទួលបានព័ត៌មាន (A2I) តាមរយៈការងារមូលដ្ឋានរបស់ខ្លួន។ ផ្អែកលើបទពិសោធន៍ដ៏ធំធេងនេះ យើងស្ថិតក្នុងកន្លែងដ៏ល្អបំផុតមួយ ដើម្បីធ្វើឲ្យសំឡេងរបស់ពលរដ្ឋសាមញ្ញ ត្រូវបានរាប់បញ្ចូលក្នុងការធ្វើគោលនយោបាយនៅថ្នាក់ជាតិ។ នៅទីនេះ យើងបានព្យាយាមគាំទ្រដល់ស្ថាប័នរដ្ឋាភិបាលឲ្យបម្រើប្រជាពលរដ្ឋស្របតាមច្បាប់និងចូលរួមចំណែកក្នុងបរិយាកាសដែលអាចឲ្យពលរដ្ឋនិងសង្គមស៊ីវិល អាចបង្ហាញការព្រួយបារម្ភរបស់ពួកគេបាន។ ទីបំផុត យើងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយពលរដ្ឋឲ្យយល់ពីសិទ្ធិរបស់ពួកគេ**<u>ការទទួលបានព័ត៌មាន</u>**និងប្រើប្រាស់ឱកាសសម្រាប់ការចូលរួម ដែលត្រូវបានផ្តល់ជូនដោយច្បាប់ផ្សេងៗ និងគោលនយោបាយរបស់រដ្ឋាភិបាល។

កម្មវិធីរបស់យើងត្រូវបានដឹកនាំដោយ វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស។ API បម្រើប្រជាជនកម្ពុជាទាំងអស់ ហើយឲ្យតម្លៃទៅលើភាពខុសគ្នា ដោយមិនប្រកាន់ភេទ និន្នាការភេទ និងអត្តសញ្ញាណ ការមានសតម្ថភាព ការអសមត្ថភាព ជាតិពន្ធ ជំនឿ និងនិន្នាការនយោបាយឡើយ។ ទន្ទឹមនឹងនេះដែរ យើងមានការប្តេជ្ញាចិត្តជាពិសេស ក្នុងការគាំទ្រដល់អ្នកដែលជួបការលំបាកបំផុត ក្នុងការខិតខំធ្វើឲ្យសំឡេងរបស់ពួកគេ ត្រូវបានគេដឹងឮ។

# ទំនាក់ទំនង

អគារ ភ្នំពេញវីឡា ផ្ទះលេខ ១២៤ ផ្លូវ ៣៨៨ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ (៨៥៥-២៣) ២១៣ ៤៨៦ ទូរសារ (៨៥៥-២៣) ២១៣ ៤៨៧

www.apiinstitute.org